# មជ្ឈមណ្ឌលឯកសារកម្ពុជា

KPI 0500

## សម្ភាសន៍ជាមួយ នាក់ នឿន ហៅ ឈូក នឿន ភេទប្រុស អាយុ៥៥ឆ្នាំ
## មុខងារនៅសម័យខ្មែរក្រហម ៖ និស្សិតបើកយន្តហោះចំបាំង
## សព្វថ្ងៃរស់នៅភូមិអូរមោសចូល ឃុំត្រពាំងរាំង ស្រុកជុំគីរី ខេត្តកំពត
## ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១១
## សម្ភាសន៍ដោយៈ ឡុង ដានី និង វ៉ាន់ថាន់ ពៅដារ៉ា
## ០០:៥៩:០៥
## ២៨ទំព័រ

ដានី ៖ ជំរាបសួរ ខ្ញុំចង់ស្គាល់ឈ្មោះពូ ឈ្មោះពេញឈ្មោះអីដែរ?

នឿន ៖ បាទ ! គឺឈ្មោះគឺ បើជំនាន់៣ឆ្នាំ គេដាក់ឈ្មោះថា នាក់ នឿន យកឪពុកធ្វើជាត្រកូល ។

ដានី ៖ ចុះឥឡូវឈ្មោះអីវិញ?

នឿន ៖ ឡូវដាក់ឈ្មោះជីតាវិញ ដាក់ឈ្មោះថា ឈូក នឿន ។

ដានី ៖ ឈូក នឿន?

នឿន ៖ បាទ ! ក្នុងអត្តសញ្ញាណប័ណ្ណរាល់ថ្ងៃ ឈូក នឿន ។

ដានី ៖ ពូ អាយុប៉ុន្មានហើយ?

នឿន ៖ បាទ ! មកដល់ថ្ងៃនេះប្រហែលជា៥៥ ។

ដានី ៖ ពូ ! ស្រុកកំណើតកើតជាពូ ប្រហែលជាភូមិស្រុកអីដែរ?

នឿន ៖ ស្រុកកំណើតកើតជាខ្ញុំ គឺភូមិអូរមោសចូលនឹង ។ អូរមោសចូល ឃុំត្រពាំងរាំង ស្រុកជុំគីរី បច្ចុប្បន្នណា ឈ្មោះភូមិបច្ចុប្បន្ន ។

ដារ៉ា ៖ ពីដើមគេដាក់ឈ្មោះអីញ្ចឹងដែរ?

នឿន ៖ ពីដើមគេដាក់ឈ្មោះ ភូមិអូរមោសចូល ឃុំត្រពាំងរាំង ស្រុកឈូក ខេត្តកំពត ខុសគ្នាស្រុក ។

ដានី ៖ អីញ្ចឹងសព្វថ្ងៃ ពូ រស់នៅក្នុងភូមិ ឃុំ ដដែល?

នឿន ៖ បាទៗ!

ដានី ៖ ប្រពន្ធពូ គាត់ឈ្មោះអីដែរ?

នឿន ៖ គាត់ឈ្មោះ ទិត ណារី ។

ដានី ៖ ពូ មានកូនចៅប៉ុន្មាននាក់ដែរ សព្វថ្ងៃ?

នឿន ៖ ខ្ញុំកូនពីរនាក់ ប្រុសមួយ ស្រីមួយ ។

Documentation Center of Cambodia
Searching for the Truth: Memory & Justice
ស្វែងរកការពិត ដើម្បីការចងចាំនិងយុត្តិធម៌
66 Preah Sihanouk Blvd. ◆ P.O.Box 1110 ◆ Phnom Penh ◆ Cambodia
t (855-23) 211-875 ◆ f (855-23) 210-358 ◆ dccam@online.com.kh ◆ www.dccam.org

ដានី ៖  ពីរនាក់ ប្រុសមួយ ស្រីមួយ?

នឿន ៖ បាទ! គេមានប្ដី គេមានប្រពន្ធគេហើយ ។

ដារ៉ា ៖ ចុះ! ពូបានជាគ្រួសារនៅឆ្នាំណាដែរ?

នឿន ៖ ខ្ញុំបានឆ្នាំ ១៩៨៨ ។

ដារ៉ា ៖ អូ! ៨៨នេះអូរ បានពូមានគ្រួសារអញ្ចឹងអូរ?

នឿន ៖ ដោយខ្ញុំជាប់ ដូចខ្ញុំបានរៀបរាប់ពីខាងលើ ជាប់ធ្វើនយោបាយ រៀនសូត្រអញ្ចឹងហើយ ខ្ញុំ អាយុ៣០ជាង បានៗយកប្រពន្ធ ។

ដារ៉ា ៖ ឪពុកម្ដាយពូ?

នឿន ៖ ឪពុកម្ដាយគាត់ស្លាប់អស់តាំងពីជំនាន់៧៩ម៉ោ ។

ដានី ៖  ឈ្មោះអីទៅ ឪពុកនោះ?

នឿន ៖ ឪពុកខ្ញុំឈ្មោះ ឈូក នាក់ ។

ដានី ៖  ឈូក នាក់ គាត់ស្លាប់ជំនាន់៧៩?

នឿន ៖ បាទៗ!

ដានី ៖  ស្លាប់នឹងដោយសារមូលហេតុអីទៅ?

នឿន ៖ ស្លាប់ដោយសារគាត់អត់បាយទទួលទាន គាត់រត់ឡើងភ្នំយើងនឹង ។

ដានី ៖  ចុះម្ដាយ?

នឿន ៖ ម្ដាយក៏គាត់ស្លាប់ដោយសារអាណឹងដែរ ។

ដានី ៖  គាត់ឈ្មោះអីដែរ?

នឿន ៖ ឈ្មោះ នួន យុត ។

ដានី ៖  ពូ មានបងប្អូនបង្កើតទាំងអស់ប៉ុន្មាននាក់ដែរ?

នឿន ៖ បងប្អូនបង្កើត៥នាក់ ។

ដានី ៖  ស្រីប៉ុន្មាន ប្រុសប៉ុន្មានទៅ?

នឿន ៖ ប្រុសបួន ស្រីមួយ ។

ដានី ៖  ពូ កូនទីម៉ាន់?

នឿន ៖ ខ្ញុំកូនទី៣ ។

ដានី ៖  កូនទី៣ អ្ហេះ?

នឿន ៖ មានបងពីរ ប្អូនពីរ ។

ដានី ៖ អីញ្ចឹងកាលពីក្មេងៗ ពូបានរៀនសូត្រអីដល់ថ្នាក់ណាដែរ?

នឿន ៖ ខ្ញុំរៀនល្មមដែរ រៀនថ្នាក់ទី៨ វត្តយើងហ្នឹង វត្តចកយើងហ្នឹង ។

ដានី ៖ រៀនថ្នាក់ទី៨ នៅវត្ត នៅវត្តអង្គចក នឹងអ្ហេរ?

នឿន ៖ បាទៗ!

ដានី ៖ ពីឆ្នាំណាដល់ឆ្នាំណា?

នឿន ៖ គឺខ្ញុំរៀនពីឆ្នាំប្រហែលជាឆ្នាំ៦៦ដល់ឆ្នាំ៧០ ព្រោះអីស្រុកខ្ញុំនេះ ឆ្នាំ៧០មានការរដ្ឋប្រហារ ខ្មែរក្រហមចុះចូល ដូចធ្វើចាប់ផ្ដើមបាញ់ប្រោកនៅភូមិនេះហើយ ។ បាទ!ខ្មែរក្រហមចាប់ផ្ដើមធ្វើសកម្មភាពមុនគេ ។

ដានី ៖ ដល់ឆ្នាំ៧០ យើងឈប់ហើយនោះ?

នឿន ៖ បាទ ! ខ្ញុំឈប់ គ្រូអីរត់ចេញអស់ហើយ រត់ចេញពីស្រុក រត់ចេញពីស្រុកនេះអស់ហើយ ។

ដានី ៖ គេបញ្ឈប់អ្ហូរ?

នឿន ៖ បាទ! គេបញ្ឈប់ ។

ដានី ៖ ដល់ពេលឈប់ហើយធ្វើអីទៀតទៅ?

នឿន ៖ បាទ! ឈប់បានប្រហែលជាជិត១ឆ្នាំ កាលណោះខ្ញុំអាយុប្រហែលជា ១៣ ១៤ឆ្នាំ ហើយគេត្រូវឲ្យចូលធ្វើជាកងទ័ពខ្មែរក្រហមធ្វើទាហានខ្មែរក្រហម ខ្ញុំទើបអាយុប្រហែលជាអាយុ១៥ កាលឆ្នាំ៧០ណុង ។

ដានី ៖ យ៉ាងម៉េច ពូអាចរៀបរាប់ឲ្យលំអិតបន្តិច មូលហេតុអីទើបបានជាពូចូលធ្វើកងទ័ពខាងខ្មែរក្រហម?

នឿន ៖ ពេលនោះគឺថាកាលៈទេសៈប្រទេសជាតិត្រូវការ បាគេមកពន្យល់ណែនាំរបបនយោបាយគេ គឺម្នាក់ៗគឺថាត្រូវចូលធ្វើជាទាហានរំដោះប្រទេសជាតិម្ដង បាតទល់ជាមួយចក្រក្រព័ត្រអាមេរិចកាំង ។

ដារ៉ា ៖ អ្នកណាចុះមកណែនាំ?

នឿន ៖ ចុះមកណែនាំ គឺកាលណោះ គឺមានមេខ្មែរក្រហម គឺស្រុកនេះមានមេ គឺថាមានមេជាប់ចលនាតាំងពី៦៧ ៦៨ មកណាស មានភ្នាក់ងារគេសម្ងាត់ កម្មាភិបាលផ្ទៃក្នុងគេអញ្ជើញចុះ ។ បាទ! សូម្បីតែ អ៊ំ ខៀវ សំផន អីក៏គាត់ធ្លាប់ចុះមកតាំងពីឆ្នាំ៦៥ ៦៧ ប៉ុន្តែកាលណុងខ្ញុំនៅតូចៗអ្ហាស ។

ដានី ៖ ពីណាគេអ្នកដែល ដូចថាអ្នកដែលនេះនឹងតាំងពីឆ្នាំ៦៧អីញ្ចឹង ពូចាំឈ្មោះគាត់ទេ?

នឿន ៖ ចាំ! ប៉ុន្តែគាត់ស្លាប់អស់ហើយ អ្នកស្រុកនឹងវ៉ាន់ អ្នកស្រុកណ្ដឹង ។

ដានី ៖ ឈ្មោះអីខ្លះទៅ?

នឿន ៖ ឈ្មោះ ខែម ឈ្មោះ ម៉ម ខែម ណ្ដឹង ឈ្មោះ គល់ ណយ គាត់អ្នកធ្វើខ្មែរក្រហមពីជំនាន់មុនណ្ដឹង ធ្វើ៦៧ ៦៨ នឹងអ្លាស ។

ដារ៉ា ៖ អ្នកទាំងអស់នឹងឯងដែលចុះមកនេះ?

នឿន ៖ បាទ! ចុះមកបំផុសបំផុល អប់រំក្មេងជំនាន់ខ្ញុំនឹងអ្លាស ។

ដារ៉ា ៖ ពូថា ខៀវ សំផន ធ្លាប់មកណ្ដឹងដែរ?

នឿន ៖ បាទៗ!

ដានី ៖ ពូធ្លាប់ឃើញគាត់ទេ?

នឿន ៖ អត់អេ្ហស ! ដល់ក្រោយមក ខ្ញុំចូលប្រឡូកប្រឡាស់ជ្រៅ ខ្ញុំធ្លាប់ឃើញ ។ ជំនាន់ណ្ដឹងលឺថាគាត់ចេះលាក់ខ្លួនម៉េច មកនៅផ្ទះណា គឺនៅណ្ដឹង ។

ដានី ៖ ចុះពូមិញ ពូគ្រាន់តែលឺថា ខៀវ សំផន គាត់ម៉ោកាលពីឆ្នាំ៦៧ ហុកអីតែមិនដែលបានឃើញ?

នឿន ៖ បាទ! អត់បានឃើញទេ គាត់លាក់ការ ការពារខ្លួនគាត់បានស្អាតណាស់ ។

ដានី ៖ ចុះកាលណុង តាខែម តាណាយ អីគាត់នៅភូមិណ្ដឹងគាត់ធ្វើអីដែរទៅ?

នឿន ៖ គាត់ជាប្រជាជនធម្មតា ។

ដានី ៖ ប្រជាជន?

នឿន ៖ បាទ! ប្រជាជនធម្មតា ប៉ុន្តែគាត់រត់ចូលព្រៃតាំងពីជំនាន់ណ្ដឹងចូលព្រៃ ។

ដារ៉ា ៖ គាត់គ្រាន់ថា យើងមើលជាលក្ខណៈប្រជាជនធម្មតា ប៉ុន្តែនៅក្នុងការផ្សារចលនាអីណ្ដឹងគឺគាត់ហ្នឹងជាមេ?

នឿន ៖ បាទៗ! គាត់ជាមេចលនា ។ ឆ្នាំ១៩៦៨ ហុកអីគាត់ចាប់ផ្ដើមមានអាវុធស្ពាយចុះមកក្នុងភូមិម្ដងៗហើយ ។ ៦៨ណ្ដឹងអ្លាស ៦៩ ឆ្នាំ៧០ គឺគាត់មានគ្នា ៣០ ៤០នាក់ ទៅ៥០នាក់ចុះអញ្ចឹងទៅៗឆាបវត្តចក ប៉ូលីសទាហានអីរត់ទៅ ។ ហើយចាប់ផ្ដើមបាញ់គ្នាទូងទាំង ទូងទាំងហើយជំនាន់ណ្ដឹង ។

ដារ៉ា ៖ តែមិនទាន់មានជាមូលដ្ឋានអេ្ហរ?

នឿន ៖ បាទ! អត់ទាន់បាញ់ម៉ាក្អែតទោរត់ទៅឡើងព្រៃបាត់ទៅ ។

ដានី ៖ អីញ្ចឹងរដ្ឋប្រហារហើយយូរអេ្ហរ បានពូចូលធ្វើកងទ័ពណ្ដឹង?

នឿន ៖ ខ្ញុំតតែឆ្នាំ៧១ ប្រហែលម៉ាឆ្នាំ ។

ដានី ៖ កាលពូចូលទៅគ្នាច្រើនអេួរ គ្នាប៉ុន្មាននាក់ដែរ? ក្នុងភូមិពូដែលចូលទៅហ្នឹង?

នឿន ៖ ខ្ញុំទៅក្មេងៗក្នុងភូមិ៥នាក់ទៅជំនាន់ខ្ញុំណុងសុទ្ធតែក្មេងៗស្រករគ្នា ។

ដានី ៖ ពូចាំឈ្មោះអេួរ អាចរៀបរាប់ឈ្មោះអេួរ?

នឿន ៖ ចាំបាន ។

ដានី ៖ ឈ្មោះអីខ្លះទៅដែលទៅជាមួយគ្នា?

នឿន ៖ ទៅខ្ញុំនឹង ឈ្មោះខ្ញុំ ឈ្មោះមួយទៀត នៅ រី មួយទៀត ង៉ែត ជា ទី៣ ខាត់ ធី ទី៤ មូល ម៉ន ។ បាទ! គាត់ស្លាប់អស់ហើយនៅតែខ្ញុំមួយទេជំនាន់ណោះ ។

ដានី ៖ អញ្ចឹងអួរទៅដំបូងទៅ៥នាក់ ទៅឥឡូវសល់តែពូម្នាក់ ចុះពូអាចរៀបរាប់ថាយើងដំបូង យើងចូលទៅដំបូងយើងថាទៅកន្លែងណាធើអី ហើយបន្ទាប់មកទៀតទៅណាទៀត?

នឿន ៖ ដោយកាលណោះខ្ញុំ ដូចជាមានភ័ព្វវាសនាម៉េចទេ ស្រាប់តែចូលទៅគ្នា៥នាក់ គេអត់ឲ្យខ្ញុំទៅធើកងទ័ពទេ ចាប់ផ្ដើមចូលគេមានឃុំមានស្រុកដូចយើងអាឡូវអញ្ចឹងអ្ហាស ។ បាទ! ដោយខ្ញុំដូចថាសាច់ឈាមរាងជិនងជាងគេ គេឲ្យធើនីរសារចៅហ្វាយស្រុក ធ្វើអង្គរក្សចៅហ្វាយស្រុកអ្ហាស បើកម៉ូតូឲ្យគេសម្រាប់រត់សំបុត្រពីស្រុកទៅឃុំ ហ្នឹងនិយាយឲ្យអស់ចុះ ។

ដានី ៖ កាលហ្នឹងស្រុកអ្នកណាគេអ្នកនេះ?

នឿន ៖ ស្រុកអួរ..គាត់ស្លាប់អស់ហើយចាស់ៗ កាលណោះគ្រូម្នាក់មកពីកំពត គាត់ធើគ្រូនៅរោងចក្រគ្រីទីង ហៅគ្រូប៉ុនៗ គាត់ចៅហ្វាយស្រុកយើងនេះ គេហៅស្រុកស្រែក្នុងជំនាន់ណោះអ្ហាស គាត់ធើជាគ្រូ ។

ដានី ៖ គ្រូអីគេ?

នឿន ៖ គ្រូប៉ុន ។

ដារ៉ា ៖ ម៉ោពីណាគាត់ណុង?

នឿន ៖ គាត់ម៉ោពីរោងចក្រីទីងយើង ក្បែរកំពត ផ្ទះកំណើតគាត់នៅស្ទឹងកែវ ។

ដារ៉ា៖ ស្រុកហ្នឹងគេហៅស្រុកអី?

នឿន ៖ ស្រុកស្រែក្នុង ។

ដារ៉ា ៖ ស្រុកស្រែក្នុងវិញ ?មិនមែនស្រុកជុំគិរី អេួរណោះ?

នឿន ៖ បាទ! មិនមែនទេ ជុំគិរីយើង កើតឆ្នាំប៉ែតម្ភ៉ាននេះហ្នឹង...។

ដារ៉ា ៖ មានលេខសំគាល់ទេ ស្រុកស្រែក្នុងហ្នឹង?

នឿន ៖ ដូចអត់មានអត្តលេខអីណាទេ ជំនាន់ណុង បើតំបន់មាន ។

ដានី ៖ ចុះលោកគ្រូប៉ុនហ្នឹងគាត់មកធ្វើគណៈស្រុកស្រែក្នុងហ្នឹងតាំងពីឆ្នាំណាម៉ោ?

នឿន ៖ គាត់ធ្វើតាំងពីឆ្នាំ ឆ្នាំចេញពីទ័ពម៉ោឆ្នាំ៧២ បា៧២ គាត់ម៉ោធើចៅហ្វាយស្រុកហ្នឹងបានយូរដែរ ។

ដានី ៖ ចុះកាលណោះ ពូស្គាល់តាផែន អ្ហេរ? ប៉ែ ផែន អ្ហាស?

នឿន ៖ ប៉ែ ផែន ដូចធ្លាប់លឺឈ្មោះដែរ ។

ដានី ៖ គាត់នៅក្នុងគណៈស្រុកហ្នឹងជាមួយគ្នាដែររឺអត់ទេ?

នឿន ៖ ប្រហែលជាក្នុងក្រុម អាក្រុមអចិន្ត្រៃជាមួយគាត់ ពិនខ្ញុំដឹងថា ប៉ុនហ្នឹងជាប្រធានហើយ ក្នុងជួរស្រុកគេ គេមានច្រើនទទួលច្រើនផ្នែកអ្ហាស អាខ្លះខាងយោធា ខ្លះខាងសង្គមកិច្ច អីៗដូចយើងរាល់ថ្ងៃ ខ្ញុំនៅស្មើរពេកខ្ញុំអត់ដឹង ខ្ញុំនៅមួយមេគេមួយ មេគេ គេចេញពីទ័ពម៉ោ ។

ដានី ៖ គ្រូប៉ុន ហ្នឹងអ្ហេស?

នឿន ៖ បាទ ! បាទ ! ហើយគេធ្លាប់ចលនាតស៊ូក្នុងព្រៃ បី បួន ឆ្នាំដែរ គេអ្នកចេះជាងគេ ។

ដារ៉ា ៖ ចុះ ប៉ុន ហ្នឹងគ្រប់គ្រងម៉ាស្រុកហ្នឹងគ្រប់ផ្នែកទាំងអស់?

នឿន ៖ គ្រប់ផ្នែក ចៅហ្វាយស្រុកគេគ្រប់គ្រង អាចៅហ្វាយស្រុកក្រោមៗទាំងអស់ គេបញ្ជាបាន ។

ដារ៉ា ៖ ចុះការផ្ញើរជានីរសាររបស់ប៉ុន ហ្នឹងអ្ហូរ ការផ្ញើរយ៉ាងម៉េចខ្លះទៅនីរសារពូ?

នឿន ៖ នីរសារ អត់មានអីសំខាន់ទេ គ្រាន់តែបំរើទឹកក្តៅ ទឹកត្រជាក់គេហ្នឹង គេមានការអី ចង់ហៅមេឃុំអីមកប្រជុំគេឲ្យសំបុត្រយើងរត់ទៅ បាទ! ជិះម៉ូតូទៅប្រាប់មេឃុំ មេអី មករៀនមកជួប ។

ដារ៉ា ៖ អញ្ចឹងដូចជាការផ្ញើរនឹងដូចជាមិនមានការលំបាកខ្វះខាត ហូបចុកអីយ៉ាងម៉េច អត់ទេអ្ហេស?

នឿន ៖ ខ្ញុំបានថាកាលនឹងជំនាន់ហ្នឹងខ្ញុំមិនមានជួបការលំបាកអីម៉ានទេព្រោះខ្ញុំនៅមួយមេគេលើដែរ

ដារ៉ា ៖ ដែលអ្ហូរ ! ជានីរសារអញ្ចឹង ពូដែលទទួលបទបញ្ជាទៅហៅមនុស្សជាអ្នកស្រុក ធម្មតាឲ្យមកស្រុកអីដែរ?

នឿន ៖ បាទ! អត់ទេ! អាហ្នឹងគេមានរយៈគេ គេមានឈ្លបភូមិ ឈ្លបឃុំគេដោយឡែកខ្ញុំមានបទបញ្ជាមួយទទួលសំបុត្រអី ពីចៅហ្វាយស្រុកទៅឲ្យឃុំគេ ។

ដារ៉ា ៖ ហើយយើងអាចដឹងពីខ្លឹមសារអីពីក្នុងសំបុត្របានអ្ហេស?

នឿន ៖ បាទ! អត់ទេ! អត់ហ៊ានទេ! កាលណោះបើសិនជាហ៊ានអញ្ចឹងគឺអស់ហើយ ចប់ម៉ង ។

ដារ៉ា ៖ ពេលទទួលសំបុត្រម្តងៗនៅលើខ្ទងសំបុត្រហ្នឹង គេមានចារដាក់ឈ្មោះចំៗអីអ្ហេស?

នឿន ៖ ចារដែរ គេដាក់ជូនអញ្ជើងទៅលោកមេឃុំនេះលោកមេឃុំនោះអញ្ជើងទៅ ឃុំត្រពាំងរាំង ឬឃុំស្រែក្នុងអី គេដាក់ចារអញ្ជើង...។

ដារ៉ា ៖ អើ..មានប្រាប់ជាឈ្មោះអីទេ ឈ្មោះបុគ្គលហ្នឹងអ្នាស?

នឿន ៖ ប្រាប់ៗ ឈ្មោះនៅហ្នឹង នៅលើស្រោមសំបុត្រហ្នឹង។

ដារ៉ា ៖ ពូអាចចាំបានទេ តើមានឈ្មោះមេឃុំណាខ្លះដែលពូធ្លាប់យកសំបុត្រទៅឲ្យ?

នឿន ៖ ភ្លេចអស់រលីងមេឃុំ ! ៣០ ៤០ឆ្នាំហើយភ្លេចអស់។

ដានី ៖ ចុះមេឃុំគាត់អ្នកស្រុកយើងដែរ ឬគាត់មកពីណា?

នឿន ៖ មេឃុំជាអ្នកស្រុកយើងទេ បើចៅហ្វាយស្រុក សុទ្ធច្រើនតែមកពីស្រុកឆ្ងាយៗ យកគ្រូៗយកអ្នកកាសែត អ្នកអីមកធ្វើចៅហ្វាយស្រុក។

ដារ៉ា ៖ ក្រោយមកទៀតពីឆ្នាំ៧២ អីហ្នឹងវិវត្តម៉េចទៀតទៅ?

នឿន ៖ ខ្ញុំនៅក្រោយ នៅមូលដ្ឋានដល់ជិតរំដោះ យើង៧៤ហ្នឹង គេរើសឲ្យខ្ញុំធ្វើទាហាន ធ្វើទាហានបាញ់គ្នារំដោះកំពតហ្នឹងអ្នាស។

ដារ៉ា ៖ ដល់ឆ្នាំ៧៤ ហើយបានគេរើសធ្វើទាហាន?

នឿន ៖ បែជនឲ្យខ្ញុំពុងហាត់ទាហាន គេរំដោះកំពត ខ្ញុំត្រូវហាត់ចុង៧៤ហើយ ៧៥រំដោះ។ ខ្ញុំហាត់ទាហានអត់ទាន់ចប់គេរំដោះកំពត រំដោះថ្ងៃ១៧មេសាឆ្នាំ១៩៧៥នោះទៅ។

ដានី ៖ កាលណោះ កាលពូគេរើសឲ្យចូលធ្វើទាហានទៅហាត់នោះ ហាត់នៅក្នុងកងណា? ហាត់នៅក្នុងកងទ័ពណា?

នឿន ៖ កាលណោះមានបងៗមកពីភាគខាងជើង ហាណូយ គេហៅហាណូយអ្នាស វាគេធ្វើគ្រូបង្ហឹកខ្ញុំនៅក្រាំងលាវ ខាងកើតកំពតនេះ មុននឹងចេញទៅប្រយុទ្ធនៅសមរភូមិមុខ ត្រូវហាត់ហ្នឹង ៦ខែ។

ដានី ៖ ហាត់ ៦ខែ?

នឿន ៖ បាទ!

ដានី ៖ ខ្មែរយើងម៉ោពីយួនខាងជើង?

នឿន ៖ បាទ! ខ្មែរយើងម៉ោពីយួនខាងជើង...។

ដានី ៖ ហាត់៦ខែ កាលណោះហាត់អីខ្លះទៅ?

នឿន ៖ មុនដំបូង ហាត់តំរៀបជួរ ឆ្វេងស្តាំបែរ អញ្ជើងទៅ បាទ !ហាត់ប្រាណហាត់អីនាយអាយអញ្ជើងទៅ អញ្ជើងហើយគេឲ្យហាត់ជាស្ពាយកាំភ្លើងយើងហ្នឹង ហាត់បាញ់ ហាត់អី ហាត់លូន

ហាត់អីអញ្ចឹងទៅ ហាត់វ៉ៃថក្រោះ ហាត់វ៉ៃសេះ អីចឹងទៅ ពេលឃើញយន្តហោះម៉ោ ធ្វើម៉េចធ្វើអីចឹងទៅ ។

ដានី ៖ កាលណោះពូនៅអង្គភាពអីគេ ឈ្មោះអីខ្វះដែរ?

នឿន ៖ កាលណោះឈ្មោះអង្គភាព៦៣ វរសេនាតូច៦៣ អនុសេនាធំ១៤០ ។

ដានី ៖ កាលណោះមានត្រឹមវរសេនាតូចទេ?

នឿន ៖ មាន ៣ វរសេនាធំដែរហើយ ខេត្តកំពតយើងហ្នឹង ។

ដានី ៖ កាលណោះ ពូនៅវរសេនាតូច៦៣ ពីណាគេប្រធានកាលណោះ?

នឿន ៖ កាលណោះ ឈ្មោះ ហ៊ិន ។

ដានី ៖ ហ៊ិន?

នឿន ៖ បាទ ! ហ៊ិន ស្រុកកំនើតគាត់ខាងទូកមាស គាត់ធ្វើគ្រូដែរ ប្រធានវរៈ ក្រោយមកពួកអាពត ចាប់គាត់ទៅឯណាឯណីទៀតទៅ ខ្ញុំក៏ខាងលើ បានប្រហែលវិលង ១ខែ ខាងលើយកខ្ញុំទៅ ភ្នំពេញទៅ ។

ដានី ៖ កាលណោះវរសេនាធំអី បី វរសេនាធំ អូសពូ?

នឿន ៖ បាទ ! បី វរសេនាធំ ខេត្តកំពតយើងហ្នឹង ។

ដានី ៖ ឈ្មោះអីខ្វះទៅ បី វរៈសេនាធំ?

នឿន ៖ បី វរសេនាធំ ប្រធានវរសេនាធំមួយឈ្មោះ ខន..ជ័យ ខន អួាស..វរសេនាធំមួយទៀត អូ្វរខ្ញុំចាំមិនបាន អ្នកស្រុកខ្ញុំនេះដែរ ។

ដារ៉ា ៖ វរសេនាធំមិញ វរសេនាធំសែម្ភ៉ាន?

នឿន ៖ អូ្វរ...១៤២..វរសេនាតូចទេ ។

ដានី ៖ វរសេនាតូច៦៣?

នឿន ៖ បាទ! វរៈសេនាតូច៦៣ ។

ដានី ៖ វរសេនាធំ?

នឿន ៖ វរសេនាធំ៤០១ ។

ដានី ៖ វរសេនាធំ៤០១ វិញ?

នឿន ៖ បាទ!

ដានី ៖ ហើយអូ្វរ..ប្រធានវរសេនាធំ?

នឿន ៖ ឈ្មោះ ជ័យ ជ័យ ខន ។

ដានី ៖ វរសេនាធំមួយទៀតឈ្មោះអីទៅ? វាមាន បី វរសេនាធំអ្ហេស?

នឿន ៖ បីវរសេនាធំ ខ្ញុំភ្លេចអស់ដែរ.. បាទ ! ភ្លេចអស់ហើយ ។

ដារ៉ា ៖ អញ្ចឹងវរសេនាធំពូ ពូអូរដែលនៅក្រោម ក្រោមហ្នឹងគឺវរសេនាធំ៤០១អ្ហេស?

នឿន ៖ បាទ! ៤០១ ។

ដារ៉ា ៖ ដែលគ្រប់គ្រងម៉ោវរសេនាតូច៦៣ អញ្ចឹងអ្ហេស?

នឿន ៖ បាទៗ!

ដារ៉ា ៖ ជ័យ ខន ហ្នឹងនៅពេញម៉ារយៈពេលហ្នឹងម្ដង ឬក៏មានការផ្លាស់ប្ដូរ?

នឿន ៖ ក្រោយមៅ ពេលសភាពការណ៍ជិតច្របូកច្របល់ដែលហើយស្រុកយើង រំដោះបាន ៧៥ ៧៦អត់ទាន់ច្របូកច្របល់ទេ ខ្ញុំផ្លាស់ទៅភ្នំពេញ ទាល់តែក្រោយមកខ្ញុំផ្លាស់ទៅស្រុកគេ ទើបបានលឺដំណឹងថា ប៉ុល ពត ចាប់យកទៅឃុំឃាំងអីណានៅគុកកំពតណុង ។

ដានី ៖ ពូអាចរៀបរាប់កន្លែងនេះ មូលហេតុអីបានពូត្រូវបានផ្លាស់ទៅភ្នំពេញ ហើយផ្លាស់ទៅថ្ងៃខែឆ្នាំណាដែរ?

នឿន ៖ កាលហ្នឹងគេរើសខ្ញុំទៅប្រហែលជា ខែ១០ ៦ យើងហ្នឹង ឆ្នាំ១៩៧៥ រំដោះហើយ នេះពីរខែបីខែហើយបានខ្ញុំត្រូវទៅនៅភ្នំពេញ ។

ដានី ៖ ម៉េចបានគេជ្រើសរើសពូទៅភ្នំពេញ?

នឿន ៖ កាលហ្នឹងមិនដឹងម៉េចដែរ ខ្ញុំភ្លាប់សភាពការណ៍មិនបានដែរ គ្រាន់តែដឹងគេថា រកមនុស្សខ្ពស់ហើយមនុស្សសុខភាពល្អ មិនសូវគ្រុនញឹកញាប់ពេក យកទៅប្រលងសុខភាពនៅក្រុងភ្នំពេញ បើមិនជាប់យើងវិលមកអង្គភាពយើងវិញ ហើយចៃដន្យអីខ្ញុំទៅក៏បានប្រឡងជាប់ទៅ ហាត់រៀននៅភ្នំពេញហ្នឹងហាត់ប្រាណហាត់អី ចេះតែហាត់រត់ហាត់អីទៅប្រឡង បានទៅស្រុកគេទៅ ។

ដានី ៖ កាលហ្នុងគ្នាម្នាំន់នាក់ដែរ ដែលរើសពីអង្គភាពពូទៅ?

នឿន ៖ អង្គភាពខ្ញុំ ប្រហែលជា៣០នាក់ដែរ ។

ដានី ៖ ប្រហែល ៣០នាក់អ្ហេរ?

នឿន ៖ បាទៗ! ទូទាំងខេត្តកំពតទាំងមូល គ្រប់វរសេនាធំ គ្រប់វរសេនាតូចហ្នឹងអ្ហាស..ម៉ា វរសេនាតូចបានមួយអីញ្ចឹងទៅ ។

ដារ៉ា ៖ ទៅនៅម្ដុំណាពូ?

នឿន ៖ ម្ដុំរាល់ថ្ងៃហ្នឹង..ចង់ភ្លេចហើយម្ដុំខាងកើតពោធិចិនតុងមក ចាស់ពីដើមគេហៅបន្ទាយប៉ារ៉ា មានរោងកុនមួយនោះ..បាទ..រោងកុននៅជើងផ្លូវ ក្រោយមកបានចេញពីប៉ារ៉ាមកនៅផ្សារពោធិចិនតុងយើងហ្នឹង គ្រូស្គាល់ទេផ្សារពោធិចិនតុង? តែអាឡូវមិនដឹងស្អីណាទេ ខ្ញុំលែងយល់ហើយ ។

ដារ៉ា ៖ ផ្សារពោធិចិនតុង នៅផ្សារពោធិចិនតុងហ្នឹង?

នឿន ៖ បាទ !ផ្សារពោធិចិនតុងហ្នឹង ។

ដារ៉ា ៖ នៅខាងកើតខាងលិច?

នឿន ៖ ខ្ញុំនៅជួរខាងជើង ខាងជើងថ្នល់ នៅផ្សារហ្នឹងម្ដង ។

ដារ៉ា ៖ នៅអូរ..ហ៊ីកហាត់ធម្មតាទេអូរ?

នឿន ៖ បាទ ! នៅហ្នឹងហាត់ធម្មតា យើងហាត់តារត់ ហាត់តាអីហ្នឹង ហាត់ប្រាណហ្នឹងអ្នាស..ហើយធើពលកម្មខ្លះ បន្តុបន្ថើនដលនៅអូរបែកក្អម អីហ្នុង ។

ដារ៉ា ៖ ហើយមានអ្នកណាគេគ្រប់គ្រងកន្លែងហ៊ីកហាត់ហ្នុងទេ?

នឿន ៖ កាលហ្នឹង..ភ្លេចហើយនាក គ្រប់គ្រងតូចតាចទេ..ខ្ញុំដឹងថាខាងលើមានតែបង ម៉េត បងផលនិងបងវ៉ៃ ពិនបងម៉េត ហ្នឹងនៅ បងផល ប្រហែលជាស្លាប់ បងវ៉ៃ ប្រហែលជាស្លាប់ ហ្នឹងកងវរសេនាធំ៥០២អ្នាស..វរសេនាធំជើងអាកាសនិយាយឲ្យចំទៅ ។

ដារ៉ា ៖ អូរ..ស៊ូ ម៉េត ហ្នឹងអ្ហេស?

នឿន ៖ បាទៗ!

ដារ៉ា ៖ គាត់វរសេនាធំអ្ហេស?

នឿន ៖ មិនមែនទេ គ្រប់គ្រងម៉ាកងជើងអាកាសទាំងអស់ កងពលធំគ្រប់គ្រងមនុស្សរាប់ម៉ឺន ប៉ុន្មានម៉ឺនទេ ខ្ញុំភ្លេចដែលហើយកាលហ្នុង ។

ដារ៉ា ៖ ស៊ូ ម៉េត គាត់ជាកងពលធំ?

នឿន ៖ បាទៗ!

ដារ៉ា ៖ កងពលអាកាសម្ដងអ្ហេស?

នឿន ៖ បាទ! កងពលអាកាស ។

ដារ៉ា ៖ អាហ្នឹង៥០២អីញ្ចឹង?

នឿន ៖ ៥០២ កងទ័ពជើងអាកាស ។

ដារ៉ា ៖ អាហ្នឹងពីឆ្នាំណាដល់ឆ្នាំណាដែរ?

នឿន ៖ ទេ! គាត់គ្រប់គ្រងរហូតគាំងរំដោះ រហូតដល់វៀតណាមវៃចូលស្រុក ។

ដារ៉ា ៖ អីញ្ចឹងអូរ?

នឿន ៖ បាទៗ! អត់មានប្រែប្រួលអីផង ។

ដារ៉ា ៖ ហើយមិញមានឈ្មោះ ម៉េត ហើយឈ្មោះអីទៀត?

នឿន ៖ មាន វៃ តែនាមត្រកូលគាត់មិនដឹងឈ្មោះអីទេ ។

ដារ៉ា ៖ តាល្វៃ អ្អូស?

នឿន ៖ តាល្វៃ គេហៅតាល្វៃ តាល្វៃ ហ្នឹង

ដារ៉ា ៖ ហើយណាទៀតទៅ?

នឿន ៖ សមាជិកកងពល គឺបងផល ។

ដានី ៖ ផល អីផល?

នឿន ៖ ឈ្មោះអីផលទេ..ភ្លេចហើយ..ច្រើនឆ្នាំអត់ដែលរំលឹក ។

ដានី ៖ មិនមែន ឯក សុផល ទេហ្អី?

នឿន ៖ មិនដឹងម៉េចដែរភ្លេចហើយ ។

ដារ៉ា ៖ ដឹងថាឈ្មោះ ផល?

នឿន ៖ បាទ ! ឈ្មោះផល ។

ដារ៉ា ៖ អីញ្ចឹងពេលដែលហាត់ហ្វឹកហ្វឺនហ្នឹងហើយ ការជ្រើសរើសទៅរៀនហ្នឹងម៉េចតទៅទៀត ទៅ?

នឿន ៖ បាទ ! មុននឹងនេះអូរ..ដុកទ័រចិនគេមកពិនិត្យសុខភាពយើង..ពិនិត្យបើសុខភាពយើងជាប់អាហ្នឹងបានទៅស្រុកគេ.. បានន័យថាគាំងពីខួរក្បាល ត្រចៀក មុខមាត់ ម៉ាដៃជើងហ្នឹង មានលក្ខណៈគ្រប់គ្រាន់ជាអ្នកបើកបរបានគេយកខុះចន្លោះណាមួយក៏មិនបានទៅដែរ ។

ដានី ៖ ឆ្នាំណាដែរដុកទ័រចិន គេមកពិនិត្យសុខភាព មកជ្រើសរើសហ្នឹង?

នឿន ៖ ឆ្នាំ៧៦ ខែ៨ យើង ។

ដានី ៖ ដល់ពេលគេមកពិនិត្យសុខភាព គេជ្រើសរើសហ្នឹងជាប់បានប៉ុន្មាននាក់ដែរ ឈ្មោះអីខ្លះទៅពូ?

នឿន ៖ អូស! ចាំអត់បានទេ..មនុស្សជិត ១០០នាក់ដែរ ខ្ញុំស្គាល់តែ ៣ ៤ នាក់តែម៉ាក្រុមខ្ញុំហ្នឹង

ដានី ៖ បាទ ! ឈ្មោះអីដែលពូស្គាល់?

នឿន ៖ ឈ្មោះ និល អូរ..វ៉ាន និល ស្រុកកំណើតនៅកំពង់ស្ពឺ អាហ្នឹងគាត់ប្រធានខ្ញុំទៅស្រុកគេដែរ

ដានី ៖ វ៉ាន និល ពីណាទៀត?

នឿន ៖ អូរ..មាស បេន ។

ដានី ៖ មាស បេន?

នឿន ៖ បាទ ! បេន ហ្នឹងនៅខាងត្បូងឈូកនោះ រាល់ថ្ងៃគាត់នៅដែរ ។

ដានី ៖ មាន បេន ហ្អី?

នឿន ៖ បាទ ! គាត់ធ្វើពេទ្យធ្វើអីនៅហ្នឹង ។

ដានី ៖ ពីណាទៀត?

នឿន ៖ ពីណាទេក្មេចអស់ទៀតហើយនឹកគិចដែរហ្នឹងណាស បេន ហើយ វ៉ន ស្អីវ៉នទេម៉ាក្រុមខ្ញុំគ្នា ៣០នាក់ដែលហ្នឹង ខាងរៀនបើកបរហ្នឹងក្មេចអស់ហើយ ។

ដានី ៖ ហ្នឹងអា..ពូរៀបរាប់ឈ្មោះ និល ឈ្មោះ មាស បេន ឈ្មោះ វ៉ន អីហ្នឹងសុទ្ធជាក្រុមរៀនបើកបរជាមួយពូហើយ?

នឿន ៖ បាទៗ!

ដានី ៖ គ្នា ៣០នាក់ទាំងអស់?

នឿន ៖ បាទ ! បាទ ! ៣០នាក់ ។

ដារ៉ា ៖ មិញ មាស បេន នៅឯណាពូ?

នឿន ៖ គាត់នៅខាងត្បូងឈូកនេះ ។

ដារ៉ា ៖ ខាងត្បូងឈូក?

នឿន ៖ បាទ!

ដារ៉ា ៖ នៅភូមិអី ឃុំអីដឹងទេ?

នឿន ៖ ប្រហែលជាភូមិ ភូមិបឹងតាមមើល ភូមិបាន្ទូវ ។

ដារ៉ា ៖ ឃុំបាន្ទូវ ចឹងអ្ហូស ។

នឿន ៖ អូឃុំព្រៃបែនទេ គ្រូ ។

ដានី ៖ ភូមិព្រៃបែនអ្ហាស ។

នឿន ៖ ភូមិព្រៃបែន ឃុំបាន្ទូវ ស្រុកឈូក បើចង់សម្ភាសន៍គាត់ទៅនឹងរកឃើញហើយ ។

ដានី ៖ ព្រៃបែន ឃុំបាន្ទូវ ហ្នឹង?

នឿន ៖ ឃុំបាន្ទូវ តាមដឹងរៀនខាងកម្មករ ។

ដានី ៖ ចុះ និល?

នឿន ៖ និល នៅឯកំពង់ស្ពឹង ណោះ ។

ដានី ៖ មានស្គាល់ស្រុកគាត់ដែរអត់?

នឿន ៖ អត់ អាួស ។

ដារ៉ា ៖ និលគាត់នៅរស់?

នឿន ៖ ស្លាប់អស់ហើយ ។

ដារ៉ា ៖ អូ និល ស្លាប់ហើយ?

នឿន ៖ បាទ!

ដារ៉ា ៖ នៅសល់តែ បែន ទេដែលនៅរស់ ។

នឿន ៖ បាទ!នៅសល់តែ បែន ទេ ភាគច្រើនស្លាប់អស់ហើយ នៅសល់តែពីរ បី នាក់ទេ ។

ដានី ៖ ចុះ វន...?

នឿន ៖ វន នឹងក៏ស្លាប់ដែរ ។

ដានី ៖ អូ...ចុះពូពេលកាលថ្ងៃ ខែ៨ឆ្នាំ៧៦កាលដែល ដុកទ័រចិនគេមកពិនិត្យ ពិនិត្យសុខភាពអីហើយ គេសំរេចឲ្យជាប់ ហើយរឿយ៉ាងម្តេច?

នឿន ៖ គេសំរេចឲ្យចាប់តែម្តង គេប្រាប់មេអ្នកដឹកនាំខ្មែរយើង ឈ្មោះនេះបានទៅ ឈ្មោះនេះមិនបានទៅ ច្នឹងនឹងណាស់ ហើយគេឲ្យយើងទ្រាប់ខ្លួន កាត់ខោអាវ សំល្បៀកបំពាក់ ទុកឡើងយន្តហោះ ក្រោយមកប្រហែលបានជាមួយខែពីរខែ យើងដឹងថ្ងៃខែដែលត្រូវឡើងយើងទ្រាប់ខ្លួនទៅ ។

ដារ៉ា ៖ ចុះពូ មានចាំថ្ងៃខែដែលពូឡើងយន្តហោះនឹងថ្ងៃណា?

នឿន ៖ ហែ ដូចជាភ្លេចដែរ ប៉ុន្តែខ្ញុំទៅបានខែត្រជាក់ដែរ ខ្ញុំខែ៩ ថ្ងៃ២៣ ចាំខែ៩ ថ្ងៃ២៣ ១៩៧៦ ។

ដារ៉ា ៖ ដែលឡើងយន្តហោះនឹងហ្វេះ?

នឿន ៖ បាទ!

ដារ៉ា ៖ តែពូ អុន គាត់ថាគាត់ឡើងយន្តហោះថ្ងៃ២៧ ។

នឿន ៖ កាលដឹងឡើងនេះច្រើនគ្នាណាស់ ធម្មតាដូចភ្ញៀវច្រើន ខ្មែរយើងទៅលាបលប់គ្នា អត់ទាន់ទៅជាដូវការ មិនមែនថាម៉ាប៉ូអីងដឹកតែនិស្សិតខ្មែរទេ ដឹក៨-១០នាក់អីទេ ។ មិនមែនដូចឥឡូវថាអីចង់អោយខ្មែរយើងទៅណា ដាក់ម៉ាប៉ូអ៊ីងទាំងអស់ កាលនឹងទៅៗក្នុងនាមលួចលាក់ឡើយនឹងណា ។

ដារ៉ា ៖ អញ្ជឹងថ្ងៃ២៣ ខែ៩ ឆ្នាំ៧៦ ថ្ងៃដែលពូឡើងយន្តហោះ?

នឿន ៖ បាទ!

ដារ៉ា ៖ ចង់សួរត្រលប់ថយក្រោយបន្តិច ពេលដែលថានៅវីកវីនអីចឹង មានការបំពាក់បំប៉នគោលនយោបាយយ៉ាងម៉េច អីយ៉ាងម៉េចខ្លះ តែដែរអី?

នឿន ៖ កាលនៅវីកវីននៅភ្នំពេញអីនោះ គេបំពាក់បំប៉នគេនិយាយពីគោលនយោបាយ ពីការកសាងប្រទេស ពីឆ្នាំណាដល់ឆ្នាំណា វាអាចការពារប្រទេសបានគេមានគោលនយោបាយគេដែរ ។

ដារ៉ា ៖ ភាគច្រើនអ្នកណាដែលជាអ្នកចុះមកបង្រៀនគោលនយោបាយបែបណឹង?

នឿន ៖ គោលនយោបាយ គឺភាគច្រើនគេគណៈចាត់តាំងគេមាន បងវៃ(តាល្វៃ) សំរាប់អប់រំបណ្តុះបណ្តាលអនុកងពល ដូចដែលខ្ញុំបានរាយនាមខាងលើណឹងបាន គាត់ទទួលភារកិច្ចខាងណឹង ។

ដានី ៖ ហើយពេលដែល មុនឡើងយន្តហោះតើមានការប្រជុំអី?

នឿន ៖ គេមានដាក់វិន័យអី ណែនាំថាម៉េចទៅខិតខំរៀន ទីពីរទៀតកុំអោយប៉ះពាល់ គោលនយោបាយអីៗពីប្រទេសមួយទៅប្រទេសមួយអីណាស គាត់ដាក់វិន័យឲ្យយើងដែរ ។

ដានី ៖ តាល្វៃ គេដាក់?

នឿន ៖ បាទ! ហើយគេហៅទូតចិនអី ណាមកធ្វើជាទីព្រឹក្សាអីដែរ យើងដែរ ។

ដានី ៖ កាលហ្នឹងពូស្គាល់ឈ្មោះ ទូតចិនដែរ?

នឿន ៖ កាលណឹងដូច លោក ហ្វាអីភ្លេចហើយ ចាំអស់បានព្រោះអីត្រកូលគេ ហ្វាញ៉ឹនម៉េចទេ ភ្លេចហើយអត់ចាំទេ ។

ដារ៉ា ៖ អីចឹងពូទៅរៀនចិន ពូចេះចិនទេ?

នឿន ៖ ចេះតិចៗដែរ ចង់ភ្លេចអស់ហើយ ចេះតែមាហូបបាយ ដើរលេង ។

ដារ៉ា ៖ ៧ឆ្នាំ ហើយគ្មានតិចឯណាពូ ។

នឿន ៖ បាទ! ចុះតាំងពីខ្ញុំត្រលប់មកវិញតាំងពី៨០ជាង មកវិញ៨២ ៨៣ហើយ ។

ដានី ៖ អញ្ចឹងពេលដែលឡើងយន្តហោះហ្នឹង មានអ្នកណាទៅជូនដំណើរអី គណៈប្រតិភូអី?

នឿន ៖ កាលណឹងមានទូតចិន និងគណៈកងពលយើង ហើយមួយទៀតផ្នែកខាងក្រសួងការបរទេសខ្មែរយើង តែមិនមែនមេមាកទេគ្រាន់តែគេធ្វើការនៅក្រសួងមន្ទីរគេណឹងណា ។

ដារ៉ា ៖ ចុះគណៈកងពលអ្នកណាគេ ចុះទៅជូនដំណើរ?

នឿន ៖ ម៉េតយើងណឹង មាស ម៉េតមិញហ្នឹង ។

ដារ៉ា ៖ ចុះខាងក្រសួងការបរទេស?

នឿន ៖ ខ្ញុំភ្លេចឈ្មោះ គ្រាន់តែគេនៅជាមួយណឹងណា បាទ!ទីព្រឹក្សាគេហ្នឹង ។

ដារ៉ា ៖ មិនមែនកំពូលដែរ?

នឿន ៖ មិនមែនកំពូលទេ អ្នកធ្វើការក្នុងមន្ទីរគេហ្នឹង ។

ដារ៉ា ៖ ពេលជិះយន្តហោះដំបូង ពូមានបានត្រលេកមើលមកខាងក្រោម?

នឿន ៖ ត្រលេកខ្លះៗដែរហ្នឹង ។

ដារ៉ា ៖ ពីមុនពូធ្លាប់ជិះយន្តហោះទេ?

នឿន ៖ អត់ទេ មិនដែលធ្លាប់ទេ ។

ដារ៉ា ៖ អត់សោះតែម្តង?

នឿន ៖ ហ្នឹង ។

ដានី ៖ អញ្ចឹងពេលដែលជិះយន្តហោះដំបូងពូមាន គិតឃើញអីមុនគេពេលហ្នឹង?

នឿន ៖ អ្ហែស គ្មានទៅគិតឃើញអីទេ គ្រាន់តែស្រណោះស្រណោកស្រុកយើង ស្រណោះស្រណោក ស្រុកកំណើតឪពុកម្តាយហ្នឹង ។

ដានី ៖ ចុះគេមានអនុញ្ញាតអោយឪពុកម្តាយចុះជូនដំណើរអត់?

នឿន ៖ អត់ទេ!

ដានី ៖ អត់ទេ អ្ហាស?

នឿន ៖ ប៉ុនខ្ញុំអរគុណ ពេលនឹងខ្ញុំរៀបចំទៅក្រៅប្រទេស គេអោយខ្ញុំមកលេងស្រុកបានជិតមួយ អាទិត្យដែរ មកលេងហ្នឹង ។

ដារ៉ា ៖ មកលេងឪពុកម្តាយហ្នឹង?

នឿន ៖ បាទ!

ដារ៉ា ៖ អញ្ចឹងពេលមកលេងក្នុងឆ្នាំ៧៦ ដែរអីចឹង?

នឿន ៖ បាទ! គេរំដោះហើយ ។

ដារ៉ា ៖ ចុះឃើញទិដ្ឋភាពក្នុងស្រុក ក្នុងភូមិ អីយ៉ាងម៉េចដែរពេលហ្នឹង?

នឿន ៖ ឃើញកាលហ្នឹង មិនដូចរាល់ថ្ងៃនេះទេ កាលហ្នឹងដូចវា ។

ដារ៉ា ៖ អត់ទេ ធៀបនឹងពេលពូចេញទៅរហូតដល់ពូមកលេងស្រុក តើថាឃើញទិដ្ឋភាពភូមិពូ ប្រែប្រួល វាយ៉ាងម៉េចអីយ៉ាងម៉េច ទីមួយដំណាក់កាលមុនខ្មែរក្រហមទទួលបានជ័យជំនះ អីចឹងទទួលបានជ័យជំនះបានប្រហែលមួយឆ្នាំអីហើយណាស វាខុសគ្នាយ៉ាងម៉េចពូសំគាល់ ទិដ្ឋភាពបែបនឹង ពូសម្គាល់ឃើញទេ?

នឿន ៖ សំគាល់ឃើញថាពេលមកនឹងឃើញបងប្អូនធ្វើការរួមដែរ ហូបបាយរួម អាណឹងខ្ញុំនិយាយឲ្យអស់ចុះ ប៉ុនដោយចៃដន្យ ខ្ញុំមកលេងផ្ទះខ្ញុំអត់បានហូបបាយរួមទេ ខាងលើបញ្ជាមកថាសរ

សេរសំបុត្រមកប៉ុនបាតដៃ ឲ្យសុំប្រធានសហករហ្នឹងហូបបាយដោយឡែក របបខ្ញុំហូបបាយមួយពេលគឺមានមាន់ មានអីធម្មតា ជីវភាពបំប៉នរៀបទៅស្រុកគេណាស នេះខ្ញុំនិយាយអោយអស់អីចឹងទៅ ។

ដារ៉ា ៖ អីចឹង?

នឿន ៖ បាទ! អីចឹងយកសំបុត្រមកប្រធានសហករណ៍គេឲ្យមួយពេលឲ្យមាន់ តិចឲ្យសាច់ជ្រូក តិចឲ្យសាច់គោអីចឹងដែរ ។

ដារ៉ា ៖ អញ្ចឹង ដែរហូបនៅផ្ទះយើងហ្នឹង?

នឿន ៖ បាទ! ហូបនៅផ្ទះ ម្ដាយខ្ញុំធ្វើអោយ ។

ដារ៉ា ៖ អីចឹងគេមិនខ្វាចថា គ្រួសារហូបអីចឹង?

នឿន ៖ អត់ៗ ខ្ញុំនៅសហករណ៍គេ ប្រធានសហករណ៍គេយោគយល់ខ្ញុំ ហើយគេដូចរៀងខ្វាចបទបញ្ជាខាងលើដែរ គេគោរព ។

ដានី ៖ ព្រោះធម្មតាយើងទៅត្រូវស្រុកក្រៅយើងត្រូវពិនិត្យសុខភាពអី គេបំប៉នសុខភាពអី ។

នឿន ៖ បាទ! គេបំប៉ន ។

ដារ៉ា ៖ មករយៈពេលប៉ុន្មានម៉ោអាទិត្យហ្អី?

នឿន ៖ ជិតម៉ោអាទិត្យ ប៉ុនខ្ញុំអត់ហ៊ាននៅបានយូរទេ ខ្ញុំប្រញ៉ាប់ទៅវិញ នៅបានតែប្រាំថ្ងៃ ។ ខ្ញុំឃើញបងប្អូនយើងលំបាកពេក វាពិបាកមើល ខ្ញុំមិនដែលឃើញសជភាពការណ៍ជាក់ស្ដែងដល់តែឃើញខ្ញុំអត់ចេះនៅ ។ ដោយសារនៅទីក្រុងភ្នំពេញ អត់ដែលឃើញប្រជាពលរដ្ឋទេ ប្អូនឯងសួរចុះ ទីក្រុងភ្នំពេញយប់ឡើងខ្ញុំអត់ហ៊ានដើរលេងផងណ្ហឹង ប្អូនដប់នាក់មិនចង់ហ៊ានដើរ ព្រោះខ្វាចខ្មោច វាងងឹត ។ ហើយពេលដែលឃើញបងប្អូនវេទនាណាស់ សាច់ សៗស្គុះ បងប្អូន១៧គេហៅថា១៧មេសានោះ បងប្អូនចេញពីភ្នំពេញនោះមកធ្វើការធ្វើអី ឃើញធ្វើការទាំងវ៉ូងៗ ខ្ញុំនៅងងឹតមុខដែរ ដូចគ្រវីក្បាលដែរ ។

ដារ៉ា ៖ កាលណ្ហឹង មានឆ្ងល់ទេ?

នឿន ៖ បាទ!

ដានី ៖ ហេតុអ្វីបានជាអីចឹង?

នឿន ៖ ដូចជាការខ្ញុំយល់ដឹងខ្ញុំនៅមានក៏វិត អត់ដូចថ្ងៃនេះនឹងហ្អាស ។ អីចឹងថាធ្វើម្ដេចសង្គមអីវាបត់បែនតាមកាលៈទេសៈ ។ ដល់ឥឡូវបានគិតថាអូ!ធ្វើចឹងខុសឆ្ងាយណាស់ អ្នកណាធ្វើបានចេះតែគិតទៅ ថាជំនាន់នោះខុសធ្ងន់ បើខ្ញុំគិតពីសម័យបច្ចុប្បន្ន ។

ដារ៉ា ៖ តែកាលពេលហ្នឹង ពីជំនាន់នឹងក្នុងជំនាន់ហ្នឹង ពូអត់បានគិតអីចឹង?

នឿន ៖ អត់បានគិតអីចឹង នឹកថាប្រវត្តិសាស្ត្រគេបត់បែនអីណាទេ ក៏អត់ហ៊ានប្រឆាំងគេ ហើយក៏អត់ហ៊ានបញ្ឆោសហករណ៍ អោយថាឲ្យបងប្អូនហូបបាយអោយឆ្អែតៗ បងប្អូនចង់ហូបអីហូបទៅអត់ហ៊ានទេ ។ បើដូចឥឡូវចេះតែសុំអង្ករ អង្ករគេពេញៗឃ្លាំង ប៉ុនឲ្យបងប្អូនហូបអត់ឆ្អែតដែរ ។ ខ្ញុំទៅលេងប្រធានសហករណ៍អីគេ ឃើញអង្ករពេញៗឃ្លាំង ។

ដារ៉ា ៖ កាលណ្ហឹងប្រធានសហករណ៍ ពូចាំឈ្មោះទេ?

នឿន ៖ គាត់រត់ចោលស្រុកបាត់ហើយ ហើយនៅបងមួយគាត់កាន់ឃ្លាំងកាន់អង្ករឈ្មោះ ហ្នឹងគាត់ចិត្តល្អទេ ឃើញគាត់ឥឡូវទៅនៅព្រំដែន ។

ដារ៉ា ៖ គាត់ឈ្មោះអីគេ?

នឿន ៖ ឈ្មោះ បង ស៊ុន គាត់កាន់ឃ្លាំងហ្នឹងណា ។

ដារ៉ា ៖ ចុះប្រធានសហករណ៍គេនោះ?

នឿន ៖ ប្រធានសហករណ៍ខ្ញុំអត់សូវស្គាល់ទេ រត់ទៅណាបាត់ហើយ នៅក្នុងស្រុកហ្នឹងដែរ ប៉ុនខ្ញុំអត់សូវស្គាល់គាត់ ឈ្មោះអីទេឈ្មោះ កាយ ។

ដារ៉ា ៖ ឈ្មោះ កាយ?

នឿន ៖ គាត់នឹងដូចអត់សូវចិត្តល្អ ប្រជាជនគេអត់សូវចូលចិត្តគាត់ ។

ដានី ៖ ប្រជាជនអត់សូវចូលចិត្តគាត់?

នឿន ៖ បាទ! អត់ចូលចិត្តគាត់អត់ចូលស្រុកវិញទៅ ។

ដានី ៖ ចុះពូមួយទៀត ដូចយើងមានសំណាងត្រូវបានជ្រើសរើសឲ្យជាប់ទៅរៀនបើកយន្តហោះអីហ្នឹង ក្រៅពីលក្ខខណ្ឌសុខភាពហ្នឹង យើងមានលក្ខខណ្ឌអីទៀត ដែលអាចថាជួយជំរុញអោយយើងជាប់ទៅហ្នឹង?

នឿន ៖ ដូចជាមិនមានលក្ខណៈអី ប៉ុនក្នុងនឹងភ្ជាប់នឹងនយោបាយខ្លះ គេថាដូចយើងជីវភាព យើងក្រក៏ជាលំដាប់ថ្នាក់អីមួយដែរ ធ្វើជីវទស្សន៍អោយអស់ចុះ ។ បើអ្នកមានក៏គេអត់យកដែរ អ្នកពាក់ព័ន្ធនយោបាយ ។ ប៉ុនមីងខ្ញុំមួយនៅភ្នំពេញ ខ្ញុំលាក់បានធ្វើប្រពន្ធសក្តិ៣ គេអត់ដឹងថាខ្ញុំមានមីងហ្នឹងខ្ញុំប្រលងជាប់ បើគេដឹងថាមីងនៅហ្នឹងខ្ញុំក៏នេះដែរ ។

ដារ៉ា ៖ ចុះបើពូមិនប្រាប់ ។

នឿន ៖ ខ្ញុំមិនប្រាប់ខ្ញុំលាក់ដែរ បងប្អូនម៉ែខ្ញុំមានបីនាក់ ខ្ញុំប្រាប់ថាបងប្អូនម៉ែខ្ញុំមានតែពីរ មានអីដឹងសំខាន់យើងចេះលាក់ដែរហ្នឹង ។

ដានី ៖ ចុះពូមានបងប្អូនអីដែរ បំរើបដិវត្តន៍អី ហើយដាកម្មាភិបាលដាន់ខ្ពស់អីដែរអី?

នឿន ៖ អត់ទេ មានទាបៗគេប្រើដែរហ្នឹង បងខ្ញុំមួយស្លាប់ដោយសារពួកហ្នឹងវៃដែរ ប៉ុនវៃមក ក្រោយនេះហើយវៃ៧៩នេះដែរ ដិនាន់គេបោសសម្អាតអីណា បងខ្ញុំពាក់ព័ន្ធគេវៃដែរទៅ ។ ហើយមេខ្ញុំៗដែលខ្ញុំនិយាយមិញហ្នឹង អត់មានសល់អីមួយ បើខ្ញុំនៅស្រុកនឹងក៏ប្រហែល ទៅនឹងគេដែល កាលនឹងខ្ញុំធ្វើមេល្មមនឹងគេដែរហើយ ខ្ញុំកាន់៣០នាក់ដែរហើយ ។

ដារ៉ា ៖ និរសាហ្នឹង?

នឿន ៖ បាទ!

ដារ៉ា ៖ និរសាកាន់៣០នាក់ដែរ?

នឿន ៖ អត់ទេ ខ្ញុំចេញពីនិរសាគេ ហើយគឺកាន់ទ័ពតែម៉ង អត់ធ្វើយុទ្ធជនធម្មតាទេ អាហ្នឹងក៏វិតតូចដង ដួនណាគេធ្វើវរៈសេនាធំ វរៈសេនាតូចដងនោះ ។

ដានី ៖ ពួកងហា កងរយ?

នឿន ៖ ធ្វើកងហា គ្រប់គ្រងគេ៣០នាក់ ។

ដានី ៖ ចុះពូ ពេលដែលចន្លោះពីមិញ ពូផ្លាស់ពីភ្នំពេញហ្នឹងពីខែ៦ (ឆ្នាំ) ៧៥ ហើយដល់ខែ៩ (ឆ្នាំ) ៧៦ បានពូឡើងកាប៉ាល់ហោះ?

នឿន ៖ បាទៗ ។

ដានី ៖ ចឹងចន្លោះពីម៉ាឆ្នាំជាងហ្នឹង ពូនៅហ្វឹកហាត់នៅពោធិ៍ចិនតុងរហូត រឺក៏មានទៅកន្លែងណា?

នឿន ៖ អត់ទេ តែកន្លែងហ្នឹង ។

ដានី ៖ នៅតែកន្លែងពោធិ៍ចិនតុងហ្នឹងហ្មង?

នឿន ៖ បាទ! មិនមែននៅទីតាំងពោធិ៍ចិនតុងនៅក្រៅ នៅផ្សារពោធិ៍ចិនតុងហើយ បន្ទាយប៉ារ៉ាហ្នឹង ។

ដារ៉ា ៖ ការដែលយើងដដែកគ្នាអាដំបូងហ្នឹង មិនទាន់មានការសម្ភាសន៍អីហ្នឹង ពូថាទៅខាងជើងទឹកអី ម៉េច?

នឿន ៖ អាហ្នឹងប្រវត្តិជើងទឹកជើងអីហ្នឹង អាហ្នឹងខ្ញុំទៅម៉ារយៈខ្លីទេ ម៉ារយៈខ្លីអីចឹងបានថាខ្ញុំ ។

ដារ៉ា ៖ ចន្លោះពេលណាពូ?

នឿន ៖ ចន្លោះពេលមុនរំដោះដែលហ្នឹង ប៉ុន្តែខ្ញុំទៅតែប៉ុន្មានខែ ដោយសារតែខ្ញុំមានបងជីដូនមួយម្នាក់ គាត់ហៅទៅនៅហ្នឹង អីចឹងបានដាខ្ញុំខ្ជិលនិយាយពីប្រវត្តិហ្នឹងហ្អាស ។

ដារ៉ា ៖ តែមុន៧៥ ហ្នឹងទេហ្អី?

នឿន ៖ បាទ! មុន៧៥ ។

ដារ៉ា ៖ ទៅខាងជើងទឹកហ្នឹង?

នឿន ៖ បាទ! គេត្រៀម បើអត់ទាន់កើតកងទ័ពជើងទឹកផង ប៉ុនគ្រាន់តែរំដោះទៅ កងហ្នឹងគេត្រៀមឲ្យនៅកងទ័ពជើងទឹក ។

ដារ៉ា ៖ អ៊ីចឹងគ្រាន់តែគេត្រៀមសម្រាប់ធ្វើជាទ័ពជើងទឹក?

នឿន ៖ បាទ! ប៉ុន្តែបច្ចេកទេសជើងទឹកហ្នឹង ខ្ញុំអត់ចេះអីតិចទេ ។

ដានី ៖ ប៉ុន្តែពូធ្លាប់ទៅនៅដល់ណាដែរ កាលហ្នឹង?

នឿន ៖ ទៅនៅខាងលិចនេះហ្អី?

ដានី ៖ អត់ទេ! ទៅនៅខាងជើងទឹក?

នឿន ៖ ជើងទឹកនៅខាងថ្នល់តារាមយើងហ្នឹង ខាងនេះហួសពីភ្នំបូកគោយើងបន្តិចហ្នឹង ។

ដានី ៖ ពូទៅនៅកន្លែងហ្នឹង បានប៉ុន្មានខែដែរ?

នឿន ៖ នៅបានពីរបីខែ ដល់សភាពការមិនស្រួល គេដកម៉េចមេៗចេញទៅ ។

ដានី ៖ គេដកម៉េចទៅ ពូអាចរៀបរាប់កន្លែងហ្នឹងបន្តិចបានទេ?

នឿន ៖ មេដូចជាថាមានក្អាក់ង៉ារ ក្អាក់ង៉ារឃ្លួនអីណាៗហ្នឹងគេដកយកទៅអប់រំអីណាទៅ អញ្ចឹងខ្ញុំមានបងប្អូនហ្នឹង គេយកខ្ញុំមកស្រុកនេះវិញទៅ ខ្លាចគេសម្លាប់អីចឹងទៅណា ។ រឿងនេះខ្ញុំមិនអាចនិយាយកើតទេ នយោបាយជ្រៅពេកខ្ញុំអត់ហ៊ាននិយាយ ។

ដានី ៖ អូ! អត់ហ៊ាននិយាយទេ?

នឿន ៖ បាទៗ!

ដានី ៖ ត្រូវជាបងជីដូនមួយរបស់ពូ?

នឿន ៖ បាទ!

ដានី ៖ គាត់ធ្វើការធំដែរ?

នឿន ៖ គាត់ធ្វើជាចៅហ្វាយស្រុកកំពត ។

ដានី ៖ គាត់ធ្វើជាចៅហ្វាយស្រុក?

នឿន ៖ បាទ!

ដារ៉ា ៖ អញ្ចឹងពេលឡើងទៅដល់ចិន ទៅដល់ដំបូងគឺនៅខេត្តណាអី ស្រុកណានៅចិនហ្នឹង?

នឿន ៖ ខ្ញុំទៅឆ្ងាយដែរលោកគ្រូ ទៅគ្រាន់សម្រាកនៅប៉េកាំងប្រហែលជាកន្លះខែជាង គេនាំដើរលេងអញ្ចឹង ក្រោយមកទៅរៀននៅស្រុកគេ ចុងខាងជើងនោះព្រំដែនសូវៀតណោះ ។

ដានី ៖ ខេត្តនោះឈ្មោះអីទៅ?

នឿន ៖ ឈ្មោះ កាឡុងចាង ខេត្តអើ ទីក្រុងហាឡាពីន ខេត្តគេកាឡុងចាង ។

ដានី ៖ ឈ្មោះភាសាចិន កាឡុងចាងអញ្ចឹង?

នឿន ៖ កាឡុចាង ។

ដានី ៖ កាឡុងចាងអ្ហ៎?

នឿន ៖ បាទ! ខេត្ត ។

ដានី ៖ ខេត្តកាឡុងចាង?

នឿន ៖ បាទ! កាឡុងចាង ទីក្រុងហាឡាពីន ។

ដានី ៖ ទីក្រុងហាឡាពីន?

នឿន ៖ បាទ!

ដានី ៖ អូ! ឈ្មោះស្រដៀងសូវៀតម៉េចទេ?

នឿន ៖ ហឺ! ចុះជាប់ព្រំដែនសូវៀតដែរ សមុទ្រខ្សាច់មាំចំហៀងម្នាក់ សមុទ្រទឹកកកអី ក៏មាំចំហៀងម្នាក់ដែរ ។

ដានី ៖ ចុះពេលពូទៅដល់កន្លែងហ្នឹង ដំបូងយើងចាប់ផ្តើមធ្វើអីខ្លះទៅ?

នឿន ៖ កាលហ្នឹងដូចជាខ្ញុំមិនទាន់ភ្លេច គឺស្រុកគេម្យ៉ាងដែរ គេឲ្យយើងហាត់ប្រាណរៀនភាសាគេទេ ។ ខ្ញុំរៀនភាសាបានមួយឆ្នាំ បានចេញមកដាក់ស្ពែង ។ ធម្មតារៀនភាសា យើងរៀនមាំឆ្នាំចេះតិចៗដែរ គេចន្លុលផង ថាផងយើងចាំបាន យើងចាប់ផ្តើមរៀនបច្ចេកទេសទៅ ។

ដារ៉ា ៖ បើនិយាយមែនទែនទៅ ពូអាចជួបការលំបាកខ្លាំងណាស់ ព្រោះពូថាពូរៀនត្រឹមថ្នាក់ទី៨ហ្នឹង?

នឿន ៖ បាទ!

ដារ៉ា ៖ ថ្នាក់ទី៨ បើយើងនិយាយឥឡូវគិតទៅថ្នាក់ទី៣ ទី៤ហ្នឹង?

នឿន ៖ បាទ!

ដារ៉ា ៖ អញ្ចឹងការចេះអក្សរវាមិនទាន់ជ្រៅជ្រះប៉ុន្មានទេ?

នឿន ៖ បាទ! អត់ទាន់ជ្រៅប៉ុន្មានទេ ។

ដារ៉ា ៖ ដល់ពេលទៅរៀនខាងបាញ់យន្តហោះ គឺសាហាវណាស់?

នឿន ៖ បាទ! សាហាវ ប៉ុន្តែមានអ្នកខ្លះអត់ចេះអក្សរទៀត ។

ដារ៉ា៖ អត់ចេះអក្សរទៀត?

នឿន ៖ បាទ! មិត្តទៅជាមួយខ្ញុំ ប៉ុនគេរៀនចេះជាងខ្ញុំទៀត រៀនភាសារៀនអី ដូចជាចាប់បានជាង ខ្ញុំទៅទៀត ខាងកំពង់ស្ពឺ កំពង់អី ប៉ុនខាងនយោបាយគេល្អ បើប្រវត្តិគេល្អគេទៅមួយខ្ញុំហ្នឹង គេអត់ចេះអក្សរអីទេ ស្រាប់តែគេបើកបរអីបានល្អចេះជាងខ្ញុំទៀត វាចេះៗទំនងដែរ ។

ដារ៉ា៖ ដំបូងពេលរៀនបច្ចេកទេសហ្នឹង បើកបរយន្តហោះហ្នឹងពូរៀនស្អីមុនគេ ជាលំដាប់លំដោយអី ចឹងមកទៀត?

នឿន ៖ លំដាប់លំដោយមើល ខ្ញុំមើលរៀនភាសា ហើយរៀនបច្ចេកទេស ។ បច្ចេកទេសនឹងបានន័យ ថា ចាប់ផ្ដើមចូលរៀនបើកបរហើយ ។ ប៉ុនមុននឹងបើកបរហ្នឹង គឺរៀនបច្ចេកទេសបើកបរបីខែ ទៀត គេយករូបយន្តហោះ រូបអីហ្នឹងយកមកដាក់លើតុហ្នឹង របៀបបើកហ្នឹង ទៅណា ឆ្វេង អាម៉េច ស្ដាំអាម៉េចអីហ្នឹង គេបង្រៀនយើងបីខែ ។

ដារ៉ា ៖ ជាទ្រឹស្ដីហ្នឹងហ្អី?

នឿន ៖ បាទ! ជាទ្រឹស្ដី ។

ដារ៉ា ៖ ហើយប្រភេទយន្តហោះយ៉ាងម៉េច?

នឿន ៖ ប្រភេទយន្តហោះ មុនដំបូងយើងរៀនអាស្លាបកាត់យើងធម្មតាA28 យើងធម្មតានឹង ។ យើងរៀនអាហ្នឹង ៥-៦ខែយើងចេះបើកបរហើយ ។ បានខ្ញុំរៀនដល់២-៣ បានចូលដល់ អាយន្តហោះដែលខ្ញុំរៀនពិតប្រាកដ ។

ដារ៉ា ៖ មុននឹងចូលដល់យន្តហោះប្រដេញ យន្តហោះអីណ្ហឹង?

នឿន ៖ បាទ!

ដារ៉ា ៖ ហើយពូអាច ពេលដែលរៀនបានប៉ុន្មានខែ បានពូអាចបើកយន្តហោះធម្មតាបាន?

នឿន ៖ ហ៎! រៀនម៉ាឆ្នាំជាង សូម្បីស្រុកគេម៉ាខែរៀនតែ៣០ម៉ោង ឡើងតែម៉ាភ្លែតៗហ្នឹង ។ ធម្មតាមានគ្រូគេពីក្រោយយើង គ្រូគេ(នៅ)ជាមួយយើងបីខែហើយ មើលយើងម្ចាស់ការ ដឹងឆ្វេងទិសដៅអីពិតប្រាកដហើយ គេក្រឡាប់កាប់ផ្ងារនៅលើអាកាសអោយយើងៗនៅតែដឹង ទិសអីកើត នឹងបានគេអោយយើងទៅហើយ គេគូសប្លង់អោយយើង ឧទាហរណ៍ចេញពី ហ្នឹងទៅភ្នំពេញចឹង តើរកភ្នំពេញឃើញដែរអត់ ។ ប៉ុន្តែគេនៅពីក្រោយយើងទេ គេលែងកាន់ ចង្កូតអីហើយណា៎ ។ ហើយដូចថាគេចេញពីភ្នំពេញទៅកំពង់សោម គេសួរថាយើងរកកំពង់ សោមឃើញដែរអត់ ។ យើងរក្សាលំនឹងទិសបានអត់ ល្បឿនបាន បើយើងរក្សារកគោលដៅ ទាំងបីនឹងឃើញ គេប្រលែងអោយយើងសាកមើលហើយ ។ ហើយដល់ចេះចុះចេះឡើងអី យន្តនឹងហើយ គេផ្លាស់យន្តមួយទៀត ។

ដារ៉ា ៖ តែដាលំដាប់យន្តហោះដូចគ្នា រឺម៉េច?

នឿន ៖ យន្តហោះខុសគ្នារហូត ។

ដារ៉ា ៖ អត់ទេ ចង់និយាយថាល្បឿនយន្តហោះ អត់ថាអាណាលឿនជាងអាណាទេ?

នឿន ៖ អត់ទេ ល្បឿនខុសជាងគ្នារហូត ដូចជាទីមួយអីចឹងម៉ោងតែបួនរយគីឡូទេ ។

ដារ៉ា ៖ ល្បឿនអស់ហើយហ្អស?

នឿន ៖ ល្បឿនអស់បំផុតហើយប្រហែលឡានយើងធម្មតាហ្នឹង ។ អាណាទីមួយណាស បើអាទីពីរ លឿនចាប់ផ្ដើម៦០០-៧០០គីឡូ អាទីបី ម៉ាម៉ោងខ្ពង់ម៉ាពាន់អីហ្នឹងទៅម៉ាពាន់ម៉ារយហ្នឹង ។

ដារ៉ា ៖ បេះហាត់រៀន ចឹងមានម៉ោងពេលអីហាត់រៀននយោបាយអីទេ?

នឿន ៖ អត់ទេ លែងពាក់ព័ន្ធនឹងនយោបាយហើយ សំខាន់អោយតែមានពេលរៀនទ្រឹស្ដីរៀនបច្ចេកទេស បានហើយទៅស្រុកគេហ្នឹង ។ ប៉ុន្ដែពីរបីខែអីចឹង មានទូតគេទៅលេងម្ដងដែរ គេប្រជុំពិសោធន៍ថា តើយើងនឹងមានបញ្ហាអី អីចឹងហ្នឹងណា៎ ការរស់នៅស្រុកគេនឹងវាម៉េច មានការលំបាករៀននឹង មានការរីកចំរើន មិនរីកចំរើនអី យើងរាយការណ៍អោយទូតចឹងដែរ ។

ដារ៉ា ៖ ទូតគេចុះទៅផ្ទាល់?

នឿន ៖ បាទ!

ដារ៉ា ៖ ទូតស្រុកចិនកាល ហ្នឹងឈ្មោះអីដែរ?

នឿន ៖ ពេជ្រ ជៀម ។

ដានី ៖ ពេជ្រ ជៀម?

នឿន ៖ បាទ! ស្រុកកំណើតគាត់នៅខាងកំពង់ចាមស្រុកកំណើត ។

ដារ៉ា ៖ ហ្នឹងទូតនៅចិន?

នឿន ៖ បាទ!

ដារ៉ា ៖ ម៉ារយៈពេលពូរៀននៅចិនហ្នឹង គឺគាត់នឹងរហូតហ្អី?

នឿន ៖ បាទ! គឺគាត់នៅរហូត ។

ដារ៉ា ៖ អ្នកស្រុកកំពង់ចាម?

នឿន ៖ បាទ! ក្រោយមកផ្លាស់ ចាប់ផ្ដើមឃ្លួនចូលស្រុកផ្លាស់ គាត់ប្រហែលជាមកធ្វើមេខ្មែរក្រហមវិញ ដាក់ ចន្ទ យ៉ូវ៉ាន់ វិញ ។ កាលមុនគាត់គ្រាន់ជាជំនួយការទូត គេហៅថាធារ៉ាក់ធារីណ្ហឹង ណា៎ ។

ដារ៉ា ៖ អូ! ធារ៉ាក់ធារី ។

នឿន ៖ បាទ! ដល់ ពេជ្រ ចៀម មកធ្វើសង្គ្រាមស្រុកខ្មែរមោក ។ ចន្ទ យ៉ូរ៉ាន់ គាត់ធ្វើទូតវិញ គាត់ធ្វើដល់ទៅយូរដែរ ធ្វើរហូតចរចាគ្នាឆ្នាំ ៩២, ៩៣ ហ្នឹងណា៎ ។

ដារ៉ា ៖ ចន្ទ យ៉ូរ៉ាន់ ហ្នឹង?

នឿន ៖ បាទ! នៅទូតស្រុកចិន ទាល់តែណាណីហ្អស ដល់អស់ខ្មែរយើងនៅឯណោះ ។

ដារ៉ា ៖ ចុះពូរៀននៅហ្នឹងរហូតដល់ពូចេះបើកយន្តហោះអីខ្លះ?

នឿនៈ ខ្ញុំចេះតែយើងធម្មតាស្ទាបកាត់យើងហ្នឹង ហើយរបស់លោកសេរីមិនសូវស្គាល់ ខ្ញុំស្គាល់ធុនប្រាំរបស់ចិន ល្បឿនអាចប្រឆាំងជាមួយអាមិចសង់តូបអីបាន ហើយនឹងអាមិចធុនប្រាំមួយរបស់ចិនណ្ហឹង ។

ដារ៉ា ៖ អាហ្នឹង ពូបើក បានន័យថាពូបើកស្ទាត់ហើយហ្នឹង?

នឿន ៖ បាទ! បើកបាន បើកម៉ាធ្វើសង្គ្រាមអី ទំលាក់គ្រាប់បែកបាន តែថាស្ទាត់មិនទាន់ស្ទាត់ទេ ព្រោះអីអារៀបមកស្រុកហ្នឹង ថារៀបយកយន្តមកធ្វើសង្គ្រាមហ្នឹងដែរ ប៉ុនដោយសារយើងចរចាថៃ អត់ត្រូវយើងសុំព្រលានយន្តហោះថៃ ចតអត់បានចឹងក៏អត់យកមក ព្រោះអីយន្តយើងរៀនចេះបាន២០គ្រឿងដែរ ។ បាទ! ដល់សភាពការណ៍ចរចាថៃក្របាន ហើយយើងនេះសភាពការណ៍ចេះទៅមុខ កុំអីក៏បានមកធ្វើអន្តរាគមន៍ម្តងៗដែរហ្នឹង ។

ដារ៉ា ៖ អីចឹងការតែពេលហ្នឹងចរចា បើថាយកយន្តហោះមក អីចឹងចុះនៅថៃហើយចឹង?

នឿន ៖ បាទ! យកថៃធ្វើឈ្នាន់ ។

ដារ៉ា ៖ មិនមែនចុះនៅភ្នំពេញយើងទេ?

នឿន ៖ ចុះអត់បានទេ នៅភ្នំពេញឯណា បើវៀតណាមនៅពេញស្រុកអស់ហើយ ។

ដារ៉ា ៖ ចុះឆ្នាំណា ពូរៀនចប់?

នឿន ៖ ការពិត ខ្ញុំត្រូវរៀនចប់ឆ្នាំ៨៥ ប៉ុន្តែដល់កាលៈទេសៈមិនទាន់ ប្រទេសកុម្មុយនីស្តមិនធម្មតាទេ ខុសពីលោកសេរីហ្អា៎ ។ ឧទាហរណ៍ថាត្រូវចឹងថារៀនដប់ឆ្នាំត្រូវចប់ គេរៀនតែ៧, ៨ឆ្នាំ គេបង្កើនម៉ោងរៀនទៀត ។ កាលពិតមួយខែខ្ញុំរៀនតែដាំងដប់ម៉ោងហ្នឹង ។ អីចឹងបានពន្យាពេល ពេលហោះហើរម្តងៗវាខូចខួរក្បាល ត្រូវចុះមកវិញបំប៉ន ធម្មតាយើងចូលក្នុងឃ្លុប យន្តវាហឹងត្រចៀក ។ អីចឹងគេអត់មានប្រើពេលយូរទេ ប្រើពេលមួយភ្លែតៗ ។

ដារ៉ា ៖ បើគិតជាការរៀនសូត្រ ពូតាំងពីរៀនបើកបរអីម៉៎ង ប្រហែលជាប៉ុន្មានម៉ោង ទើបពូអាចបើកបរបាន?

នឿន ៖ កាលហ្នឹងគិតប៉ុន្មានប្រាំរយម៉ោង ប៉ុន្មានថ្ងៃទេ ខ្ញុំភ្លេចហើយ ។

ដារ៉ា ៈ បានតែប្រហែលប្រាំរយម៉ោងទេ ម៉ារយៈពេលពូទៅរៀនហ្នឹង?

នឿន ៈ អត់ទេ ខ្ញុំគិតតែរឿងយន្តល្អទេ យន្តក្រោមខ្ញុំអត់គិតទេ សំរាប់យើងហាត់រៀនមុនដំបូងខ្ញុំអត់គិតទេ ភ្លេចហើយ ។ យន្តល្អគេរៀនតែប្រាំរយម៉ោង ព្រោះយើងមានទុនពីដើមមកហើយហ្នឹង អាក្រោយៗគ្រាន់តែយើងរៀនបន្ថែម ព្រោះទិសដៅ គោលដៅអី លំនាំទិសអី យើងដឹងអស់ហើយ ល្បឿនអីអាណាយើងដឹងអស់ហើយហ្នឹង គ្រាន់តែយើងដឹងថា ទាញជំនាញអារបស់លឿនត្រូវធ្វើម៉េច តែប្រាំរយម៉ោងទេ ។ ប៉ុនបើកាលៈទេសៈបន្ទាន់ ដូចអាកាលហ្នឹងគេអត់រៀនដល់បួនរយផង គេរៀនតែបីរយម៉ោង គេទំលាក់ភ្នំពេញបែកដូចតែគ្នាហ្នឹង ខុសខ្លះត្រូវខ្លះទៅ ប្រទេសកុម្មុយនីស្តវាអីចឹង ។

ដារ៉ា ៈ អាទំលាក់ហ្នឹងគេមើលម៉េចអោយទំលាក់បានត្រូវ ព្រោះវាលឿនហើយវាខ្ពស់ទៀត?

នឿនៈ វា សំខាន់! បច្ចេកទេសដោយឆាយ បើនិយាយពីឥឡូវប្រទេសគេជឿនលឿន គេប្រើតាំងពី ៣០ឆ្នាំមុន តាំងពីខ្ញុំនៅរៀន ដែលប្រទេសយើងគេប្រើរាល់ថ្ងៃ គេប្រើតែប្រព័ន្ធគេហ្នឹង អត់មានចាំអីទេ ហើយមិនបាច់ចាំមើលគោលដៅ មើលដាក់ស្ពែងអីផ្សារវត្តុចកអីទេ គេមើលតែក្នុងផែនទី ហើយល្បឿនយន្តហោះគេ នាឡិកាគេណា ហើយកុំព្យូទ័រគេនៅនឹងម៉ាស៊ីនគេហើយហ្នឹង ។ សួរថាចេញពីប៉េកាំងមកភ្នំពេញប៉ុន្មានម៉ោង ថាប្រាំម៉ោងចឹងមើលថា គត់ប្រាំម៉ោង ចុកទៅចំហើយភ្នំពេញហ្នឹង កុំព្យូទ័រគេឆ្លើយត្រង់ណាស់ ខុសៗតិចណាស់ ។ បាទៗ ហើយរក្សាគោលដៅបាន ថាមកពីភ្នំពេញហ្នឹង គោលដៅភ្នំពេញម៉ារយហុបសិបអង្សា ឬក៏ម៉ារយហាអីចឹង រក្សាគោលដៅហ្នឹងអោយបាន ។

ដារ៉ា ៈ ចុះម៉េបានដឹងថា នៅភ្នំពេញហ្នឹង យើងត្រូវហោះមួយរយហា ឬមួយរយហុកអីចឹង មានស្អីប្រាប់យើង?

នឿន ៈ កុំព្យូទ័រ! ហ៊ឺស! ធម្មតាគេមុននឹងចេញ គេគូសផែនទីអីហើយអស់ហើយលោកគ្រូ ផែនទីដាក់នៅមុខយើងនឹង នៅដាក់មុខៗ ដូចថាលោកគ្រូចេញពីភ្នំពេញមកដល់អន្គតាសោម ត្រូវប្រើរយៈពេលប៉ុន្មាន ប៉ុន្តែរក្សាល្បឿនអោយបានមិនដូចយើងនៅដីទេណា នៅនឹងដីគេហៅស្ទះចរាចរ នៅលើអត់ស្ទះទេ ហើយថាទៅដល់ណាម៉ោងណាគឺម៉ោងនឹងហើយ ។

ដារ៉ា ៈ ហើយចឹងនៅក្នុងផែនទីៗលើក្រដាសហ្នឹង ពេលវាស់ទៅ គេអាចដឹងចំងាយ?

នឿន ៈ បាទ! ដឹងចំងាយ ហើយយើងប្រើល្បឿនតាមចំងាយណ្ហឹងទៅ ហើយគោលដៅយើងធម្មតាដូចខ្ញុំបាននិយាយអំបាញ់មិញអីចឹង ថាមកភ្នំពេញទិសវាប៉ុន្មានៗអីចឹងណា ។ បាទ! ជុំវិញ

ដែនដីយើងមានបីរយប៉ុន្មាន ៦០អង្សាយើង ថាមកភ្នំពេញមានប៉ុន្មានអង្សា រក្សាទិសនោះអោយត្រង់ណ្ហឹងឃើញ ។

ដារ៉ា ៖ ឲ្យចំមក?

នឿន ៖ បើចំមកដល់ហើយ ។

ដារ៉ា ៖ ចឹងពីចិនមកភ្នំពេញ គេវាស់ហើយ វាស់ពីចិនមកភ្នំពេញ យន្តហោះនៅប៉េកាំងហ្នឹង ចេញមកដល់ភ្នំពេញពោធិ៍ចិនតុង ចំងាយប៉ុណ្ណឹង ចំងាយប៉ុន្មានគីឡូម៉ែត្រ អីចឹងហ្អី?

នឿនៈ បាទ! ឧទាហរណ៍ទេ ។

ដារ៉ា ៖ ឧទាហរណ៍ ហើយដល់ពេលអីចឹងយន្តហោះយើងត្រូវបើកម៉ោម៉ោងប៉ុន្មានល្បឿនវា ហើយទូទាត់គ្នាទៅ ត្រូវបើក ឧទាហរណ៍ថាប្រាំម៉ោងចំតែម្តង ចំទិសដៅវាម៉ង?

នឿនៈ បាទៗ!

ដារ៉ា ៖ អីចឹង អោយតែបើករក្សាល្បឿនបានប៉ុណ្ណឹង លំនឹងអីបានប៉ុនណ្ហឹង កំពស់អីប៉ុនណ្ហឹង ហើយដល់អាម៉ោង៥ហ្នឹងគត់ហើយ គឺថាភ្នំពេញហើយចឹង?

នឿនៈ បាទៗ! ប៉ុន្តែមានផលខ្យល់ប៉ះពាល់ទៀត អាហ្នឹងទុកអោយម៉ាស៊ីនគេទូទាត់អោយយើង ក្រែងយើងគិតគូរមិនដល់ ម៉ាស៊ីនទូទាត់អោយយើង អាចលើកខុះមួយរយម៉ែត ឬ ពីររយម៉ែតលោកគ្រូណាស ។ ធម្មតាធ្វើដំណើរឆ្ងាយ ហើយខ្ពស់ ផលប៉ះពាល់នៃខ្យល់វាមាន ។ អាណ្ហឹងម៉ាស៊ីនកុំព្យូទ័រយើងនៅហ្នឹងគេឆ្លើយអោយយើងហើយ សំខាន់ម៉ាស៊ីនទេ ប៉ុន្តែយើងនៅនឹងផ្លូវយើងក៏អត់ចោលវាដែរ អាហ្នឹងបច្ចេកទេស ។

ដារ៉ា ៖ ពូរៀនវាច្រើន គ្រាន់តែខ្ញុំឆ្ងល់ទេ ។

នឿន ៖ បាទ! បើប្រើខួរក្បាលទាំងអស់វាទៅមិនរួចទេ សំខាន់ម៉ាស៊ីនវាជួយ ។

ដានី ៖ ចុះរបៀបទៅទំលាក់នោះ ឧបមាថាយើងបើកចឹង ពេលទំលាក់យើងសំកាំងយន្តហោះ ឬក៏យ៉ាងម៉េច?

នឿនៈ អត់! គ្រាន់តែយើងទៅដល់គោលដៅយើងមិនសំកាំងទេ ព្រោះវាអាចគេបាញ់យើង បើយើងហ៊ានណាស់គ្រាន់តែបន្ថយល្បឿនតិចៗ ល្បឿនមាំពាន់គីឡូក្នុងមួយម៉ោងចឹង យើងដាក់៨០០-៩០០អាចយើងយកគោលដៅអោយបានលេខមួយណា៎ អានឹងវាល្អជាង ។

ដារ៉ា ៖ តែអាហ្នឹងយើងហោះខ្ពស់ណាស់ពូ?

នឿន ៖ ហោះខ្ពស់ដែរ ។

ដារ៉ា ៖ ហោះខ្ពស់ តែម៉េចគោលដៅ ក៏ដាក់ត្រូវកើត?

នឿនៈ  អាហ្នឹងអីចឹងហើយដែលត្រូវការហាត់រៀន ខ្ញុំហាត់ទំលាក់រាប់ពាន់គ្រាប់ហើយ ជួនណាហួសតែគោលដៅផ្ទះខ្ញុំ ទំលាក់ផ្សារវត្តចក ។ ជួនណាចង់ទំលាក់ឯនេះ នោះទំលាក់ភ្នំហួស អាហ្នឹងត្រូវការប៉ាន់ស្មាន អានឹងនិយាយអោយអស់ទៅ ។

ដារ៉ា :  ស្មានគោលដៅ យើងស្មានធៀបទៅនឹងស្អី?

នឿនៈ  ធៀបនឹង ធម្មតាមុននឹងយើងចេញហោះហើរ ខុតុនិយមគេអោយហើយ ផលប៉ះពាល់មានតែខ្យល់ម៉ាមុខ យន្តហោះអីចឹង គ្រាប់ស្អីក៏ដោយ ឧបស័គ្គមានតែខ្យល់ទេ ។ បើថ្ងៃណាខ្យល់វាមានល្បឿនក្នុងមួយម៉ោងប៉ុន្មានម៉ែត្រចឹងទៅ យើងតាមគោលដៅដែលគេអោយមកអីចឹងមក បើថ្ងៃណាអស់សូវមានខ្យល់ យើងមកហោះរៀបដល់ផ្ទះនឹង ចាំទំលាក់ក៏បានដែរ ខ្ទះពីរបីរយម៉ែត្រពីនោះមកចាំចុចទៅ ចុកកុងតាក់ទៅ ល្បឿនយន្តហោះរៀងខ្យល់ ហើយនឹងគ្រាប់វាមកដំណាលគ្នាហ្នឹង ដល់វាធ្លាក់បេះតែឆ្ងាយពីយន្តហោះយើងទៅ វាមកតាមធម្មតា ។

ដារ៉ា :  ចឹងពូមកដល់ភ្នំពេញវិញ មកដល់ស្រុកខ្មែរ ខែណា ឆ្នាំណា ថ្ងៃណា?

នឿនៈ  ខ្ញុំមកវិញ អត់បានចូលស្រុកយើងផង ខ្ញុំចូលបាងកកឯណោះហ្នឹង ដោយសារខ្ញុំនិស្សិតកុម្មុយនីស្ត និស្សិតខ្មែរក្រហម ។

ដារ៉ា :  ឆ្នាំណា ខែណា ថ្ងៃណា ពូត្រលប់មកវិញ?

នឿន :  ខ្ញុំមកវិញ ៨២ ខែ១ ។ ខែ១ ៨២ ចឹងចុះ ។

ដានី :  មកដល់ស្រុកខ្មែរយើងវិញ?

នឿន :  បាទ!

ដារ៉ា :  ចង់និយាយថាមកពីស្រុកចិនវិញ?

នឿន :  បាទៗ! ។

ដារ៉ា :  ចុះមកចុះនៅឯណា?

នឿនៈ  ចុះនៅបាងកក ។

ដារ៉ា :  ហើយមានគេទៅទទួលអីទេ?

នឿនៈ  មានទូតខ្មែរយើងនៅឯងបាងកកហ្នឹង សក្កិប្រាំ សក្កិបួន ទាហានថៃ គេទៅស្ពាយយើងចេញពីព្រលានយន្តហោះចូលបន្ទប់ចេញពីព្រលានចឹងមក ។

ដារ៉ា :  ប៉ុន្មាននាក់ទៅ?

នឿន :  កាលហ្នឹងមកម្តង១៨នាក់ លាយឡំជនបរទេសហ្នឹង កុំឲ្យគេដឹងថាជាខ្មែរជាអីចឹងលាក់ការណ៍ ។

ដារ៉ា :  ចឹងមកចូលបាងកកចឹង?

នឿន ៖ បាទ!

ដារ៉ា ៖ ចុះជំនាន់ហ្នឹង មានទូតដែរ?

នឿន ៖ មានតើ ។

ដារ៉ា ៖ ៨២ហ្នឹង?

នឿន ៖ ៨២ ទូតខ្មែរក្រហមនៅថៃ ខុះអីផ្ទះសំណាក់គេប៉ុនៗណាណី ។

ដានី ៖ ឈ្មោះអីគេ អ្នកទូតនៅថៃ?

នឿន ៖ ដូចឈ្មោះលោក ប៊ុន ។ ប៊ុន គាត់ស ទាបបន្តិចខាងកំពង់ចាមដែរ ។

ដារ៉ា ៖ ចឹងទំនាក់ទំនងការទូតអី រវាងខ្មែរក្រហម របបកម្ពុជាប្រជាធិបតេយ្យជាមួយនឹងថៃ នៅមានត មករហូត?

នឿន ៖ បាទ!

ដារ៉ា ៖ ចឹងពេលដែលពូចូលមកដល់បាងកក ស្ថានទូតគេទៅយក?

នឿនៈ បាទ!

ដារ៉ា ៖ មកដល់ស្រុកថៃអីទូតខ្មែរទៅទទួលពូយកមកវិញចឹង បន្តទៀតទៅណាទៅ?

នឿន ៖ គេអោយសំរាកផ្ទះសំណាក់គេ កន្លះយប់ ដល់ម៉ោងបីជិតភ្លឺ តូយ៉ូតាគេដឹកយកមកដាយដែនមក ។

ដារ៉ា ៖ នៅជំរំណាពូ?

នឿន ៖ អត់ជំរំណា ដឹកមកដាយដែន ដាក់ជំរំខ្មែរក្រហម ដាយៗដែនយើងហ្នឹង ។

ដានី ៖ ម្តុំណាដែរទៅ?

នឿនៈ ហ្នឹងគេហៅម្តុំ ជួរភ្នំដងរែក គេហៅម្តុំខាងលិចសំឡូត ម្តុំលោកបងធំទី១នៅហ្នឹងណា៎ អាច-១ ច-២គេហ្នឹង ដែលដឹងទេ ។

ដានី ៖ អូ! ដែលពូ ។

នឿន ៖ ដែលពូ ចុះនឹង មានច្រកហ្នឹងមួយ ហើយហ្នឹងច្រកខាងលិច ។

ដារ៉ា ៖ ចុះពេលនោះពូធ្វើអីវិញហើយចឹង?

នឿន ៖ អត់មកធ្វើអីផង គេអោយមកយាមឃ្លាំងយាមអីនៅនោះ ។

ដារ៉ា ៖ គេមិនអោយបើកយន្តហោះទេ?

នឿន ៖ អត់ទេ មានយន្តហោះឯណា យាមឃ្លាំងគ្រាប់យើងហ្នឹង យាមមី យាមអីៗណា ។

ដានី ៖ យាមកន្លែងគាៗ?

នឿន ៖ បាទៗ! ប៉ុននៅឆ្ងាយណាស់ គេអត់ទុកយើងជិតទេ នៅប្រហែលគេមានកងការពារជនជាតិ ២-៣ជាន់ កន្លែងតាៗនោះ ។

ដានី ៖ តាៗ មានកងការពារជនជាតិអី?

នឿន ៖ ជនជាតិ ខ្មែរលើយើងហ្នឹង ។

ដារ៉ា ៖ ជនជាតិភាគតិចហ្នឹង?

នឿន ៖ បាទៗ គាត់កងការពារគាត់នឹង ។ ខ្មែរយើងអី អើណាអត់បាននៅជិតគាត់ទេ ។

ដានី ៖ ពូស្គាល់ តា ចៀម ដែរទេ?

នឿន ៖ អត់ ដូចអត់ស្គាល់ទេ ស្គាល់តាឡាំង តាឡាំងមេកងការពារគាត់ណ្ហឹង ពួកជនជាតិដែរ ។

ដារ៉ា ៖ តាឡាំង តាឡាំងហ្នឹង ដូចឡើងជំនួសតាអី តាយ៉ា ពេលតាយ៉ា គេចាប់ខ្លួនទៅ តាឡាំងឡើង អីចឹងតាឡាំងមកដល់សំឡូតអី មកការពារ ការអីធំដែរ?

នឿន ៖ ដឹកមកដល់ ប្រហែលជាគាត់បានធ្វើធំចេញពីហ្នឹងដែរ ។

ដារ៉ា ៖ តាឡាំង អីចឹងហ្អី?

នឿន ៖ បាទ! ឈ្មោះ ឡាំង មេកងការពារ ។

ដានី ៖ ចុះពូនៅអាហ្នឹងរហូតដល់ពេលណាទៅ?

នឿន ៖ ខ្ញុំបើនិយាយឲ្យអស់វែងឆ្ងាយដែរតើ ដូចអាសារខ្ញុំគិតយូរៗទៅការខ្ញុំស្វែងយល់ ចេញពីចិន ចេញចូលមកខ្មែរហើយ ចូលទៅថៃញីញាប់ទៅ ។ ខ្ញុំស្វែងយល់ទៅថាធ្វើសង្គ្រាមមិនឈ្នះ សម្តេចនាយកទេ ខ្ញុំចេញពីជួរ ខ្ញុំរត់ទៅនៅជរំ ។ និយាយឲ្យអស់ ខ្ញុំឈប់តស៊ូអីទៀតហើយ ការប្រពន្ធបានប៉ុន្មានខែ យើងតស៊ូអត់ឈ្នះគេទេ ទៅធ្វើជនសាមញ្ញធម្មតា រកស៊ីវិញ ។ ទៅរកស៊ីធ្វើខ្ញុំថៃ ដកដំឡូងដកអី នៅលាងចានអោយគេអីនៅតាមហាងទៅ ។

ដារ៉ា ៖ យើងផ្តាច់ខ្លួនចឹងមក គេអត់តាមរកតាមអី?

នឿន ៖ គេតាមរកដែរ រកអត់ឃើញខ្ញុំចូលទៅជ្រៅ ខ្ញុំឆ្លាតដែរ មានទៅក្បែរៗអី ទៅធ្វើខ្ញុំគេកណ្តាល រំលងម៉ាខេត្តអីនោះ ។

ដារ៉ា ៖ ចុះពូមកស្រុកទេស ស្រុកភូមិពូវិញនៅឆ្នាំណា?

នឿន ៖ ខ្ញុំមកមុនបោះឆ្នោតបន្តិច មកកាលវីកអ៊ិតាក់គេដឹកមកហ្នឹង ៩២ ។

ដារ៉ា ៖ កាលមាតុភូមិនិវត្តន៍ហ្នឹងហ្អី?

នឿន ៖ បាទ! មាតុភូមិនិវត្តន៍ ។

ដារ៉ា ៖ ជនភៀសខ្លួន?

នឿន ៖ បាទៗ មកជំនាន់នឹង ។

ដារ៉ា ៖ មកនេះបណ្ដោយ?

នឿន ៖ បាទ! មកស្រុកមក ហ្នឹងនិយាយឲ្យអស់ ។

ដារ៉ា ៖ រឿងហ្នឹងវាមិនជាប់ពាក់ពន្ធ័អីទេ គឺគ្រាន់តែថាវាជារឿងប្រវត្តិសាស្ត្ររៀបរាប់តាមសាច់រឿង ជាលក្ខណប្រវត្តិសាច់ជាលក្ខណៈប្រវត្តិសាស្ត្រ ។

នឿន ៖ បាទ! អាហ្នឹងជាប្រវត្តជីវិតរបស់ខ្ញុំដោយសង្ខេបអីចឹងចុះ ។ អីជួយផ្ដល់ពត៌មានអីតិចតួច ។

ដារ៉ា ៖ ពួកខ្ញុំដូចជាអត់មានចម្ងល់អីទៀតទេ ទាក់ទងទៅនឹងការងាររបស់ពូពីជំនាន់៣ឆ្នាំ ព្រោះថាពូប្រហែលជា ។ សូមសួរបន្តិច ចន្លោះពេលដែលពូទៅរៀនណា៎ ដូចថាមានស្ថានទូតអីគេទៅប្រជុំទៅអីដែរអីចឹងមិនចឹង ។ គេខាងស្ថានទូតខ្មែរ ពេលហ្នឹងបានរាយការណ៍ពីសភាពការណ៍អីពីស្រុកខ្មែរយើងដែរ?

នឿន ៖ បាទ! រាយការណ៍ដែរ ។

ដារ៉ា ៖ ភាគច្រើនរាយការណ៍ពីអី?

នឿន ៖ រាយការណ៍ថា ការអភិវឌ្ឍន៍អី រីកចំរើនមហាលោតផ្លោះមហាអស្ចារ្យ នៅខាងស្រុកនេះមានប្រឡាយ ប្រជាជនអីហូបបាយមួយថ្ងៃមានបីពេលអីចឹងទៅណា ហើយខ្ញុំចេះតែជឿទៅ ។ មហាលោតផ្លោះមហាអស្ចារ្យ ពូថាយកអ៊ីៗដែលគេយកទៅនោះហើយ គេប្រាប់យើងថាល្អ ។ ដំណឹងល្អៗសម្រាប់ឲ្យយើងខំរៀនណា៎ មានដឹងសភាពការណ៍អីចឹងឯណា ។ ហើយរាយការណ៍ចឹង ហើយពង្រឹងយើងឲ្យខំរៀនតែប៉ុណ្ណឹងនឹង អាងមកការពារប្រទេសណា៎ ។ ហើយគេប្រាប់អីចេះដែរ គេថាខំរៀនទៅសមមិត្តអីឯណាយួនកំពុងតែវ៉ៃ កាលនោះចាប់ផ្ដើមវ៉ៃអីបណ្ដើរៗ មិនទាន់មានលក្ខណៈធំទេណា៎ ៧៦អីហ្នឹងណា៎ គ្រាន់តែរតេតរតូតតាមព្រំដែនតែអ្នកនយោបាយជំនាន់ហ្នឹង គេត្រៀមហើយ គេដឹងថាប្រទេសខ្មែរយើង គេញូមិនផុតពីប្រទេសវៀតណាមលុកលុយយកប្រទេសខ្មែរទេ ។ គេត្រៀមហើយ គាពគគាត់បញ្ញាដែរ គាត់មិននេះប៉ុន្មាន ។ ប៉ុនដោយសារកាលៈទេសៈ វាបន្ទាន់ពេក យើងពង្រឹងផ្នែកយោធាអត់ទាន់ ចឹងបានកាលៈទេសៈហ្នឹងវាអីចឹង ។ ហ្នឹងទូតគេទៅបង្រៀនខ្ញុំដាក់ស្ដែងចឹង គេមានតែឲ្យខ្ញុំខិតខំរៀនតែប៉ុណ្ណឹង ។

ដារ៉ា ៖ បើចឹងពួកខ្ញុំ ដូចអត់មានអីសួរពូ ច្រើនលើសហ្នឹងទៀតទេ ចឹងសូមអរគុណពូច្រើន ដែលបានផ្ដល់ព័ត៌មាន ។

នឿន ៖ បាទ! សូមអរគុណ ។

ដានី ៖ បាទ! អរគុណច្រើន ៗ

«ចប់»